**មជ្ឈមណ្ឌលដើម្បី សន្តិភាព និង អភិវឌ្ឍន៍**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំ ខប់សែលប្រ៉ែម

## យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃពុធ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**ខេត្ត ព្រៃវែង**

**ខប់សែល ដំណាក់កាលទី ២**

COPCEL Phase II

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

**របៀបវារៈ**

១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោក **ឡារី ស្រេ្តន្ទ** នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភុវឌ្ឍន៍កម្ពុជា (CDRI)

២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក **ឱក សេរី សោភក្តិ៍** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការ ខប់សែល នៃវិទ្យាស្ថាន CDRI

៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក **ហួត ផាន** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តព្រៃវែង

៤. មតិរបស់អ្នកចូលរួមដែលបង្ហាញពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតនៅក្នុងបរិបទខេត្តព្រៃវែង

៥. សេចក្តីផ្សេងៗ

---

## ១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោក ឡារី ស្រេ្តន្ទ នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភុវឌ្ឍន៍កម្ពុជា (CDRI)

លោក **ឡារី ស្រេ្តន្ទ នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍** (CDRI ) លោកបានធ្វើការគោរពស្វាគមន៍ចំពោះ អស់លោក លោកស្រី ដែលមានវត្តមាននៅក្នុងថ្ងៃប្រជុំទាំងអស់។ ខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះឯកឧត្តមអភិបាលខេត្ត ឯកឧត្តម អ៊ុក សាមិ និងនាយរងខុទ្ទកាល័យរបស់ឯកឧត្តមដែលបានគាំទ្រអនុញ្ញាត្តិអោយវិទ្យាស្ថាន CDRI រៀបចំការប្រជុំនៅក្នុងខេត្តព្រៃវែងនេះ និងសូមថ្លែងអំណរគុណចំពោះលោក ហួត ផាន ជាប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតនៅក្នុងខេត្តព្រៃវែងនេះ។ លោកបានជម្រាបជូនថា ហេតុអ្វីបានជាវិទ្យាស្ថាន CDRI រៀបចំកម្មវិធីខប់សែល ហើយជាពិសេសខប់សែលនៅថ្នាក់ខេត្តយើងនេះ។ វិទ្យាស្ថាន CDRI ជាវិទ្យាស្ថានមួយធ្វើការស្រាវជ្រាវដោយឯករាជ្យទៅលើគោលនយោបាយ ដើម្បីរៀបចំគោលនយោបាយសម្រាប់រៀបចំការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាដែលវិទ្យាស្ថាន CDRI មានមូលដ្ឋាននៅទីក្រុងភ្នំពេញ។ វិទ្យាស្ថាន CDRI បានធ្វើការសិក្សាស្រាវជ្រាវទៅលើ វិស័យ៥ដែលជាវិស័យសំខាន់ៗនៅក្នុងការអភិវឌ្ឍន៍នឹងធ្វើអោយមានភាពរីកចំរើននៅប្រទេសកម្ពុជា។ វិស័យដែលខាង CDRI បានសិក្សាស្រាវជ្រាវមានដូចជា ផ្នែកខាងអភិវឌ្ឍន៍ សេដ្ឋកិច្ចពាណិជ្ជកម្ម ជាពិសេសពាណិជ្ជកម្មនៅក្នុងតំបន់ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍កសិកម្ម ហើយនឹងការបង្កើននៃមុខរបរការចិញ្ចឹមជីវិត ការអភិបាលកិច្ចប្រកបដោយលទ្ធិប្រជាធិតេយ្យ និងកំណែទំរង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ហើយនិងចំនុចចុងក្រោយគឺសន្តិសុខរបស់មនុស្ស និងការកសាងសន្តិភាព និងការដោះស្រាយទំនាស់។ នៅក្នុងវិស័យទាំងអស់នេះវិទ្យាស្ថាន CDRI បានធ្វើការយ៉ាងជិតស្និតជាមួយគ្រប់ភាគីពាក់ព័ន្ធនៅក្រុងព្រះរាជាណាចក្រកម្ពុជាយើងនេះ។ ជាពិសេសភាគីពាក់ព័ន្ធដែលជាដៃគូរបស់វិទ្យាស្ថាន CDRI មានដូចជារាជរដ្ឋាភិបាល ខាងស្ថាប័ននានាជុំវិញការងារអភិវឌ្ឍន៍ ខាងសង្គមស៊ីវិលខាងស្ថាប័នឯកជន ក៏ដូចជាស្ថាប័នជាតិនិងអន្តរជាតិផ្សេងៗផងដែរ។ វិទ្យាស្ថាន CDRI គឺធ្វើការនៅក្នុងក្របខ័ណ្ឌមួយឯករាជ្យនិងអព្យាក្រឹត្យហើយអ្វីដែលវិទ្យាស្ថាន CDRI បានជឿជាក់នៅក្នុងបេសកម្មរបស់ខ្លួននោះ គឺការអភិវឌ្ឍន៍នានាទាំងឡាយអាចប្រព្រឹត្តិទៅបាន លុះណាតែយើងមានការកសាងសន្តិភាព និងការអភិបាលកិច្ចប្រកបដោយលទ្ធិប្រជាធិតេយ្យដែលជាក្បាលម៉ាស៊ីនមួយដ៏សំខាន់ក្នុងការឈានទៅរកការអភិវឌ្ឍន៍។ វិទ្យាស្ថាន CDRI យល់ថាការរៀបចំការបោះឆ្នោតដោយរលូនត្រឹមត្រូវនិងយុត្តិធម៌និងមានប្រសិទ្ធភាព គឺជាយន្តការមួយឆ្ពោះទៅរកការកសាងនូវលទ្ធិប្រជាធិតេយ្យមួយដ៏ពិតប្រាកដ ដែលលទ្ធិប្រជាធិតេយ្យអាចជាក្បាលម៉ាស៊ីនមួយឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបទៅដោយស្ថេរភាព។ ដោយផ្អែកទៅលើទស្សនៈនេះហើយបានជា វិទ្យាស្ថាន CDRI

បានរៀបចំនូវកម្មវិធីកិច្ចប្រជុំខប់សែលទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ខេត្ត ជាពិសេស ទាំងនៅថ្នាក់មូលដ្ឋាន ហើយដែល អស់លោក លោកស្រីចូលរួមនៅពេលនេះគឺកិច្ចប្រជុំថ្នាក់ខេត្តក្រុង។  យើងគិតថាការដែលផ្តល់ឱកាសជូនចំពោះភាគីពាក់ព័ន្ធនានាជាពិសេសភាគី ភាគីពាក់ព័ន្ធជុំវិញរឿងបោះឆ្នោតនេះ ដើម្បីមានឱកាសលើកយកបញ្ហានានា ឬការប្រឈមមុខនានា យកមកពិភាក្សានៅចំពោះមុខគ្នា ដោយត្រង់ទៅត្រង់មកដោយបើកចំហរ នេះជាចំនុចមួយដ៏មានសារៈសំខាន់។ កម្មវិធីរបស់វិទ្យាស្ថាន CDRI ទាំងអស់គឺទទួលបាន ការគ្រាំទ្រយ៉ាងពេញទំហឹង និងយ៉ាងខ្លាំងពីសំណាក់រដ្ឋាភិបាល ជាពិសេសក្រសួងមហាផ្ទៃ ពីសំណាក់អាជ្ញាធរខេត្តក្រុង និងជាពិសេសពី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលយើងហៅថា គជប ។ វិទ្យាស្ថាន CDRI បានចាត់ទុកថា ជារឿងមានសារៈសំខាន់ ណាស់របស់ ខប់សែល ព្រោះធ្វើការដើម្បីគោលបំណងក្នុងការកសាងនូវវប្បធម៌នៃការពិភាក្សាគ្នានៅចំពោះមុខដោយត្រង់ៗនេះ ដែលជាមូលដ្ឋាមគ្រឹះមួយនៅក្នុងការជំរុញអោយមានសន្តិភាព។  ក៏ប៉ុន្តែការជោគជ័យទាំងឡាយនៅក្នុងការជជែកពិភាក្សាគ្នានៅក្នុង ខប់សែល នេះ គឺអស់លោក លោកស្រី ដែលចូលរួមយ៉ាងសស្រាក់សស្រាំនៅក្នុងពេលនេះដែលយើងមានបញ្ហាប្រឈមមុខអ្វីផ្សេងៗ ទៀត។

## ២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម (COPCELPROM) ដោយលោក ឱក សេរី សោភ័ក្តិ ទីប្រឹក្សា និងជាអ្នកសំរបសំរួល យន្តការ ខប់សែល នៃវិទ្យាស្ថាន CDRI

**លោក ឱក សេរី សោភ័ក្តិ** បានថ្លែងនូវអំណរគុណ ចំពោះ លោក ឡារី ស្រ្តេន្ទ ដែលលោកមានប្រសាសន៍យ៉ាង ក្បោះក្បាយហើយមានអត្ថន័យយ៉ាងជ្រាលជ្រៅចំពោះយន្តការខប់សែលនេះ។ លោកបានជម្រាបត្រួសៗថា តើយន្តការ ខប់ សែល នេះកើតឡើងដូចម្តេច ? ហើយពីពេលណាមក ? លោកបានជម្រាបថា នៅឆ្នាំ១៩៨១លោកបានធ្វើការតស៊ូនៅជាយដែន នៅពេល នោះហើយដែលឃើញថាក្រោយពេលដែលយើងទទួលរបបសង្គ្រាមប្រល័យពូជសាសន៍របស់ពលពតរួចមក និងដោយឃើញប្រជាជន យើងត្រូវគេធ្វើបាបខ្លាំងណាស់នៅក្នុងជំរំ ការដែលត្រូវគេធ្វើបាបនោះគឺ អស់កិត្តិយសក្នុងឋានៈជាប្រជាជននៅក្នុងប្រទេសមួយ ការ ដែលយើងត្រូវសុំទានពិភពលោកដើម្បីរស់ ហើយចេះតែគិតថានៅពេលយើងបានសន្តិភាពត្រឡប់មកវិញ តើយើងធ្វើយ៉ាងណាដើម្បី កុំអោយត្រឡប់ទៅក្នុងយុទ្ធសម័យនោះទៀត។ នៅពេលដែលអ៊ុនតាក់រៀបចំការបោះឆ្នោតនៅឆ្នាំ១៩៩៣ ឯកឧត្តម ស ខេង ជាមួយ និង សម្តេច ហ៊ុន សែន លោកបានស្នើរសុំ យើងបានជួបគ្នាធ្វើការពិភាក្សាថា ឥឡូវយើងចប់សង្គ្រាមហើយ សូមអោយខ្ញុំចូលមកធ្វើ ការនៅក្នុងរាជរដ្ឋាភិបាលទៅ ខ្ញុំក៏ព្រមធ្វើជាទីប្រឹក្សានិងនាយកខុទ្ទកាល័យរបស់ឧបនាយករដ្ឋមន្ត្រី ហើយដែលកាលនោះជាសហរដ្ឋ មន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម ស ខេង ខ្ញុំបាទធ្វើការនោះ៥ឆ្នាំ ពីឆ្នាំ១៩៩៣ដល់ឆ្នាំ១៩៩៨។ ហើយឯកឧត្តមបានប្រគល់ភារៈកិច្ចការ បោះឆ្នោតឆ្នាំ១៩៩៨នោះអោយមកដល់ក្រុមការងារមួយដែលខ្ញុំបាទជាអ្នកដឹកនាំ នៅឆ្នាំ១៩៩៣យើងដឹងស្រាប់ហើយគេរៀបចំអោយ យើងទាំងអស់ ប៉ុន្តែប្រាំឆ្នាំក្រោយមកឆ្នាំ១៩៩៨នោះយើងរៀបចំខ្លួនឯង ហើយយើងចាប់ផ្តើមគិតពីឆ្នាំ១៩៩៣នោះថា បើយើង មិនមានបទពិសោធន៍សោះ តើយើងរៀបចំការបោះឆ្នោតយ៉ាងណា ? ប៉ុន្តែនៅពេលដែលធ្វើការ៥ឆ្នាំ ជាមួយរាជរដ្ឋាភិបាលហ្នឹង លោក បានគិតហើយថា តើហេតុអីបានជាសង្គ្រាមនៅស្រុកយើងមានដល់ទៅ២៨ឆ្នាំ ? ភាពខ្លោចផ្សា និរាស ព្រាត់ព្រាស់មិនចេះចប់មិនចេះ ហើយ។ នៅពេលដែលចេញពីរាជរដ្ឋាភិបាល៥ឆ្នាំហើយ លោកក៏បានមកធ្វើការនៅវិទ្យាស្ថាន CDRI នេះ ជាអ្នកសំរបសំរួលខាងកម្ម វិធីអភិវឌ្ឍន៏ និងសន្តិភាព នៅឆ្នាំ១៩៩៩រហូតដល់ឆ្នាំ២០០៣ គឺនៅពេលនោះហើយដែលវិទ្យាស្ថាន CDRI បានធ្វើការស្រាវជ្រាវ មួយស្តីពីទំនាស់ដែលកើតឡើងនៅក្នុងការបោះឆ្នោតនៅកម្ពុជា។ ហើយលោកក៏បាននឹកឃើញថា ដើម្បីអោយការបោះឆ្នោតនេះលែង មានទំនាស់ទៀត លោកបានគិតថាអាកប្បកិរិយា និងវប្បធម៌របស់ខ្មែរយើងមិនសូវចូលចិត្តនិយាយគ្នាត្រង់ទៅត្រង់មក មិនចូលចិត្ត យកបញ្ហាដែលជាទំនាស់ហ្នឹងយកមកដាក់លើតុដើម្បីនិយាយគ្នាទេ។ យើងចូលចិត្តញញឹមដាក់គ្នានៅនិងមុខ ប៉ុន្តែក្រោយខ្នងយើងចូល

ចិត្តនិយាយដើមគ្នាណាស់។ លោកគិតថាការធ្វើដូច្នេះ នាំអោយមានការយល់ច្រឡំច្រើន នាំអោយមានទំនាស់កាន់តែច្រើន ដូច្នេះហើយបានជាលោកចេះតែស្រម៍យថា ចង់ឃើញយន្តការមួយ ជាពិសេសនៅជុំវិញការបោះឆ្នោតហ្នឹង ដែរតួអង្គទាំងអស់ ទាំងគណបក្សនយោបាយ ទាំងអង្គការសង្គមស៊ីវិល ទាំង គជប ទាំងរាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន អង្គុយនៅជុំវិញតុហើយលើកនូវបញ្ហាអ្វីដែលស្តាប់គ្នាមិនបាន យកមកដាក់ ហើយជជែកគ្នាត្រង់ទៅត្រង់មក ដើម្បីបណ្តុះនូវវប្បធម៌ជជែកពិភាក្សាគ្នាត្រង់ទៅត្រង់មក។ ការពិភាក្សានេះហើយដែលនាំអោយយើងទុកចិត្តគ្នាបាន ព្រោះជួនកាលយើងមិនបានជជែកគ្នាយើងចេះតែចោទគ្នាទៅវិញទៅមក ដល់ពេលដែលយើងជជែកគ្នាទៅ ទោះបីជាយើងមិនស្រុះស្រួលគ្នាមែន តែយើងចាប់ផ្តើមយល់ថា ហេតុអីបានម្នាក់ទៀតគេមានយោលបល់ខុសពីយើង ? ពេលនោះហើយដែលយើងចាប់ផ្តើមគោរពភាពខុសគ្នានៃការយល់ឃើញរបស់យើងម្នាក់ៗ ហើយយើងក៏ចាប់ផ្តើមទុកចិត្តគ្នាថា ការខុសគ្នាមិនមែននាំទៅរកជំលោះទេ ការខុសគ្នានេះហើយដែលនាំអោយយើងកាន់តែយល់ចិត្តគ្នាឡើង អោយសង្គមរបស់យើងកាន់តែជឿនលឿនឡើង បានជាមានយន្តការ ខប់សែល នេះឡើង។ ហើយយន្តការខប់សែល ដំណាក់កាលទី១ បានចប់នៅខែកញ្ញា ឆ្នាំ២០០៣។ លោកក៏មានមោទនភាពដែរ ព្រោះយន្តការនេះគឺបង្កើតឡើងដោយដៃខ្មែរខ្លួនឯង ប៉ុន្តែនៅឆ្នាំ ២០០៤នោះ ដោយសារ UNDP ជាពិសេសលោក Douglas Gardner នោះខាងអង្គការសហប្រជាជាតិនៅញូយ៉កគាត់បានឃើញសេចក្តីរាយការណ៍ហ្នឹង គាត់ក៏បានមកជួបជាមួយលោក ឡារី ស្រ្តេន្ទ ហើយនិងរូបលោក គាត់ថាយន្តការនេះល្អណាស់ដែលខ្មែរយើងបង្កើតដោយខ្លួនឯង ហើយមិនដែលឃើញប្រទេសណាដែលទើបនឹងចេញពីសង្គ្រាម ហើយអាចរកយន្តការមួយ និយាយស្តាប់គ្នាបានតាំងពីថ្នាក់លើដល់ថ្នាក់ក្រោមបានទេ។ បានជាគាត់សុំអោយវិទ្យាស្ថាន CDRI ហើយនិងរូបលោកធ្វើបន្តទៅទៀត ដើម្បីបំរើការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ដែលនឹងរៀបចំឡើងនូវថ្ងៃទី១ខែមេសាឆ្នាំ២០០៧ខាងមុខនេះ ហើយនឹងការបោះឆ្នោតថ្នាក់ជាតិនៅប្រហែលជាខែកក្កដាឆ្នាំ២០០៨។ យើងខ្ញុំក៏ធ្វើការស្រាវជ្រាវខ្លះ ហើយក៏សុខចិត្ត ប៉ុន្តែម្តងនេះកាលដំណាក់កាលទី១ យើងមិនបានចុះមកធ្វើនៅខេត្តទេ ៤ឆ្នាំយើងប្រជុំគ្នា៥០ដងរាល់ខែមិនដែលខានទេ ប៉ុន្តែយើងធ្វើតែនៅថ្នាក់ជាតិទេនិង បញ្ចប់នៅឆ្នាំ២០០៣ ក្រោយពេលបោះឆ្នោត។ ដល់កាលដំណាក់កាលទី២នេះ ខ្ញុំបាទគិតថាទំនាស់ដែលកើតឡើងពិតប្រាកដក្នុងយន្តការបោះឆ្នោតនៅកម្ពុជាគឺកើតឡើងនៅថ្នាក់មូលដ្ឋាន ដូច្នេះបើសិនជាយើងបង្ការទំនាស់នៅថ្នាក់មូលដ្ឋានបាន នោះបានទៅថ្នាក់ជាតិមិនមានបញ្ហា។ អញ្ចឹងហើយបានជាខប់សែលបំបែកខ្លួនចេញពីខប់សែលថ្នាក់ជាតិមកខប់សែលប្រ៊ម អោយតម្លៃទៅលើយន្តការបង្ការទំនាស់នៅក្នុងថ្នាក់ខេត្តហ្នឹង ដោយមានការចូលរួមពីក្រុមប្រឹក្សាឃុំសង្កាត់ និងពីបណ្តាស្ថាប័នផ្សេងៗដូចពេលនេះ។ នៅក្នុងកាលដំណាក់កាលទី២នេះ យើងធ្វើមានគោលដៅធំ៣គឺ :

ទី១ គឺការចុះឈ្មោះបោះឆ្នោត គឺធ្វើយ៉ាងណាអោយគ្រប់គ្នាដែលដល់អាយុ១៨ឆ្នាំ ត្រូវតែទៅក្រុមប្រឹក្សាឃុំសង្កាត់ដើម្បីចុះឈ្មោះបោះឆ្នោត មិនចាំបាច់អោយនរណាមកហៅទេ ព្រោះជាតួនាទីរបស់ប្រជាពលរដ្ឋ។ ត្រៀម៩ខែ ពីខែមករាដល់ខែកញ្ញា យើងទៅចុះឈ្មោះទៅ ហើយដល់ថ្ងៃទី០១ដល់ថ្ងៃទី២០ខែតុលាយើងទៅចុះឈ្មោះជាផ្លូវការទៅ។ ដូច្នេះប្រជាពលរដ្ឋត្រូវតែស្គាល់ពីសិទ្ធិពីកត្តាបកិច្ចរបស់ខ្លួន ត្រូវតែទៅបំពេញតួនាទីរបស់ខ្លួន កុំចាំទាល់តែដល់ពេលហើយចាំទៅបន្ទោស គជប បន្ទោសក្រុមប្រឹក្សាឃុំសង្កាត់ បន្ទោសស្មៀនឃុំសង្កាត់ថាមិនចុះអោយឡើយ យើងជាប្រជាពលរដ្ឋយើងត្រូវតែទៅព្រោះជាតួនាទីរបស់យើង។ ដូច្នេះការចុះឈ្មោះបោះឆ្នោតហ្នឹងត្រូវតែជាកាយវិការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

ទី២ យើងបានធ្វើការជាមួយក្រសួងមហាផ្ទៃ យើងបានជជែកគ្នា៣ខែតាំងពី២០០៥ នៅថ្នាក់ជាតិអំពីរឿងអត្តសញ្ញាណប័ណ្ណជាតិ។ យើងគិតថាប្រជាពលរដ្ឋដែលមិនមានអត្តសញ្ញាណប័ណ្ណជាតិគ្រប់ៗគ្នាជាការពិបាកណាស់ ហើយការបោះឆ្នោតដែលប្តូរពីប័ណ្ណបោះឆ្នោតមកប្រើអត្តសញ្ញាណប័ណ្ណនេះប្រជាពលរដ្ឋត្រូវតែមាន ដោយយើងជជែកគ្នាច្រើន ហើយធ្វើកំណត់ហេតុនោះជូនទៅ

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីទៅ លោកក៏យល់ឃើញសារៈសំខាន់នៃអត្តសញ្ញាណប័ណ្ណនេះ បានជាដើមខែមករាដើមឆ្នាំ២០០៦នេះ លោកបើកយុទ្ធនាការខ្លាំងត្រូវតែធ្វើអត្តសញ្ញាណប័ណ្ណមួយឆ្នាំហ្នឹងសម្រាប់អ្នកដែលនៅសល់១លាន៩សែននាក់។ ដូច្នេះប្រជាពលរដ្ឋខ្មែរអោយតែដល់អាយុ១៨ឆ្នាំ ត្រូវតែបានទទួលអត្តសញ្ញាណប័ណ្ណ មានអត្រានុកូលដ្ឋាន មានសំបុត្រកំណើត រៀបការត្រូវតែមានសំបុត្រ ប្តូរអាស័យដ្ឋានក៤ត្រូវតែទៅសាលាឃុំដើម្បីប្តូរ រឿងអស់នេះនឹងក្លាយទៅជាទម្លាប់របស់ពលរដ្ឋដែលជឿនលឿននិងមានអរិយធម៌ពិតប្រាកដ។

គោលដៅទីពារបស់ខប់សែលគឺធ្វើយ៉ាងណា រូបភាព១៩៩៨ដែលពិភពលោកបានទទួលទាំងប៉ុន្មាន គឺធ្វើយ៉ាងណាសូមអោយរលាយបាត់សូន្យ ជំនួសដោយវប្បធម៌នៃការពិភាក្សា ជំនួសដោយវប្បធម៌សន្តិភាព។ នៅខេត្តក្រចេះ កំពង់ចាម UNDP ២នាក់បានមកចូលរួមប្រជុំជាមួយយើង ម៉េចបានជាគាត់មកប្រជុំជាមួយយើង គាត់ថាយន្តការខប់សែលនេះជាយន្តការតែមួយគត់ដែរប្រទេសក្រោយសង្គ្រាមហើយអាចបង្កើតយន្តការហ្នឹង ជជែកជាមួយគ្នាបាន ជជែកក្នុងរឿងក្តៅគគុក ប៉ុន្តែនៅក្នុងភាពថ្លៃថ្នូរហើយនិងគោរពគ្នាទៅវិញទៅមក។

### ៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក ហួត ផាន ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តព្រៃវែង

**លោក ហួត ផាន** បានបង្ហាញពីសកម្មភាពនៃការរៀបចំការបោះឆ្នោតកន្លងមក និងដំណើរការនៃការរៀបចំការបោះឆ្នោតនាពេលបច្ចុប្បន្ននេះ នៅក្នុងខេត្តព្រៃវែង

ទី១ ពីផែនការស្ថិតិ នៃការពិនិត្យ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៦ ខេត្តព្រៃវែងមាន១២ស្រុកមាន ១១៦ឃុំ មាន១១៣៧ភូមិ មានប្រជាពលរដ្ឋរួមចំនួន ១លាន៨០ពាន់៦៩១នាក់ មានប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើងមាន៦១២ពាន់ ៥២០នាក់ ពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីឆ្នាំ២០០៥មាន ៥៨៤ពាន់២២០នាក់។ ក្នុងផែនការអ្នកដែលដល់អាយុថ្មីនិងអ្នកដែលមិនទាន់ចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០០៦នេះមាន២ម៉ឺន៦៩៥នាក់។ ការចុះឈ្មោះឆ្នាំនេះគិតថ្ងៃ០១ដល់ថ្ងៃ២៤ខែតុលាឆ្នាំ២០០៦ បានចំនួន១០៨ពាន់៤២២នាក់ លើសអំពីផែនការដែលបានគ្រោងទុក។ ការកែតំរូវឈ្មោះបាន២៣០ពាន់៥៧នាក់។ លុបឈ្មោះសរុបបាន ៨១០៧នាក់ ក្នុងនោះស្លាប់ ៤០០៦នាក់ ផ្លាស់ចេញ៣ពាន់ ៥២៧នាក់ ឈ្មោះស្ទួន៥៦១នាក់ និងដកសិទ្ធ១១នាក់។

ទី២ ការិយាល័យចុះឈ្មោះឆ្នាំ២០០៦ ត្រៀមសំរាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំសំរាប់ឆ្នាំ២០០៧។ មុនពេលចុះឈ្មោះ គជប បានផ្តល់ការិយាល័យអោយគណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្តនេះ១២៣៧ការិយាល័យ។ តែដល់ពេលចុះឈ្មោះស្មៀនឃុំយើងមិនបានចុះឈ្មោះ២ការិយាល័យ គឺនៅការិយាល័យលេខ១២២២នៅក្នុងឃុំគោកខ្ពស់ខាងកើត និងការិយាល័យលេខ១២១៥ក្នុងឃុំកោះចេក។ ក្រៅពីនោះស្មៀនឃុំបានចុះឈ្មោះលើសពីចំនួនកំណត់ ចំនួន៧០០នាក់ចំនួន៥ការិយាល័យទៀត គឺនៅឃុំស្រែកោង ការិយាល័យលេខ០០៥២ ឃុំប្រាសាទស្រុកកំពង់ត្របែក ការិយាល័យលេខ០២១៤៥ ឃុំកោះសំពៅស្រុកជើងជ ការិយាល័យលេខ០៤៩៣ ឃុំកញ្ជំស្រុកពារាំងការិយាល័យលេខ០៦០៣ និងឃុំស្មោងខាងជើងការិយាល័យលេខ០១៦១។ ដូច្នេះ គជប និងបំបែកការិយាល័យទាំង៥នេះ អោយទៅជាការិយាល័យភ្លោះនៅពេលបោះឆ្នោតក្រុមប្រឹក្សាឃុំខាងមុខ។ សរុបការិយាល័យបោះឆ្នោតក្រុមប្រឹក្សាឃុំនៅពេលខាងមុខនេះអាចមានរហូតដល់ទៅ១ពាន់៣៤០ការិយាល័យនៅទូទាំងខេត្តព្រៃវែង។

រាល់ការចុះឈ្មោះនិងបោះឆ្នោតកន្លងមកតែងតែកើតមានបញ្ហាទំនាស់បន្តិចបន្តួច ដែលបញ្ហាទំនាស់ទាំងនោះ សិតតែបានសម្របសម្រួលនៅថ្នាក់ PEC និងថ្នាក់ CEC ។ ព្រោះទំនាស់តូចតាចយើងអាចរកវិធីដោះស្រាយបាន ដោយឈរលើស្មារតីយោគយល់គ្នា។

## ៤. មតិរបស់អ្នកចូលរួមដែលបង្ហាញពីការប្រឈមនានាក្នុងយន្តការរៀបចំការបោះឆ្នោតនៅក្នុងបរិបទខេត្តព្រៃវែង

លោក **ហង្ស យ៉ុន** ជំទប់ទី១ ឃុំកំពង់លាវ ស្រុកកំពង់លាវ បានមានប្រសាសន៍ទាក់ទងទៅនិងជំលោះនៃការចុះឈ្មោះបោះឆ្នោតទៅអោយជនជាតិវៀតណាម លោកបានស្តាប់អង្គការក្រៅរដ្ឋាភិបាលមានលោក គល់ បញ្ញា ដែលគាត់មិនបានផ្សព្វផ្សាយអោយបានយល់ដឹងតាមរយះការផ្សព្វផ្សាយនេះ ហើយថ្ងៃនេះជាឱកាសមួយល្អណាស់ព្រោះចង់ឮតែម្តង តើយើងដោះស្រាយយ៉ាងម៉េច ? ដែលវាមិនមែនជាការឈានទៅរកជំលោះទេ ។ ក្នុងការចុះឈ្មោះបោះឆ្នោតឱ្យជនជាតិវៀតណាម យើងខ្ញុំពិបាកណាស់សព្វថ្ងៃនេះពិព្រោះបើបន្ទោសអ្នកចុះនោះអត់ត្រូវទេ ប៉ុន្តែពេលនេះខ្ញុំសូមធ្វើអនុសាសន៍ដល់ឧបសែលអោយនាំនូវសំនូមពររបស់យើងខ្ញុំទៅជូនក្រសួងមហាផ្ទៃ អោយគាត់ធ្វើច្បាប់មួយទៀតអោយបានច្បាស់លាស់ ព្រោះច្បាប់សព្វថ្ងៃថាអោយវៀតណាមចុះឈ្មោះបោះឆ្នោតនេះ តាមខ្ញុំពិនិត្យមានពីទិន្នភាព ទីមួយគឺទាក់ទងនឹងច្បាប់សញ្ជាតិរូបណីកម្មនេះ រដ្ឋសភាបានសម្រេចអនុម័តនៅថ្ងៃ២០ខែសីហាឆ្នាំ១៩៩១នីតិកាលទីមួយអង្គប្រជុំវិសាម័ញ្ញ ក្នុងនោះគេចែងថា មុននឹងចូលសញ្ជាតិបាន ហើយបើវៀតណាមចង់ចូលសញ្ជាតិខ្មែរទាល់តែមានឡាយព្រះហត្ថលេខាពីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នេះទីមួយ។ ហើយទី២ អ្នកដែលចូលសញ្ជាតិត្រូវតែស្បថនៅមុខតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកជនជាតិវៀតណាមដែលក្រុមប្រឹក្សាយើងខ្ញុំបានចុះឈ្មោះបច្ចុប្បន្ននេះ យើងខ្ញុំមានការលំបាកណាស់ យ៉ាងម៉េច ? ដូចខ្ញុំលើកទិន្នភាពច្បាប់២ដែលខ្ញុំលើកខុសគ្នា គឺខ្ញុំនិយាយទៅលើច្បាប់គោល ច្បាប់រដ្ឋធម្មនុញ្ញ មួយទៀតសំអាងថាក្រសួងមហាផ្ទៃមានលក្ខខ័ណ្ឌដែលត្រូវមានសិទ្ធចុះឈ្មោះបោះឆ្នោតនោះតើមានអ្វីខ្លះ? ឧទាហរណ៍មាន អត្តសញ្ញាណប័ណ្ណ មានបញ្ជីជាតិ មានប័ណ្ណកូនសិស្ស មានប័ណ្ណមន្ត្រីរាជការ។ តែនៅក្នុងច្បាប់ដែលខ្ញុំមើលមិនមានចែងពីរឿងហ្នឹង ដល់មិនមាន ខ្ញុំសួរថាហេតុអីក៏លោកហ៊ានចុះ ? គាត់ឆ្លើយថាធ្វើម៉េចបើគេមិនទាន់មានច្បាប់មកអោយគេចុះអញ្ចឹងទៅ។ ដូច្នេះសូមអោយធ្វើការរៀបចំច្បាប់នេះអោយបានច្បាស់លាស់។

លោក **ចាន់ ចន** ស្នងការរងនគរបាលខេត្តព្រៃវែង លោកបានមានប្រសាសន៍ទាក់ទងទៅនិងរឿងអត្តសញ្ញាណប័ណ្ណ យើងបានធ្វើ២ឆ្នាំមកហើយ ប៉ុន្តែកន្លងទៅយើងធ្វើតាមការផ្សព្វផ្សាយអោយដល់ប្រជាពលរដ្ឋដើម្បីអោយគាត់មកធ្វើ ទៅតាមលទ្ធភាពរបស់តំណាងរាស្ត្រដែលមាន យើងមានសំភារៈបំពាក់ធ្វើអត្តសញ្ញាណប័ណ្ណនេះនៅខេត្តព្រៃវែងយើងមានតែមួយគ្រឿងទេ ហើយមួយគ្រឿងនេះយើងត្រូវចល័តធ្វើនៅទូទាំងខេត្ត ដូច្នេះការធ្វើគឺមានការយឺតយ៉ាវ ហើយមួយទៀតដោយសារប្រជាពលរដ្ឋយើងមិនទាន់យល់ច្បាស់ពីសារៈប្រយោជន៍នៃការធ្វើអត្តសញ្ញាណប័ណ្ណនេះ គាត់អាងតែគាត់អាចដើរហើរបានដោយមិនចាំបាច់មានលិខិតស្នាមឆ្លងទៅដល់ថៃ ឆ្លងទៅដល់ម៉ាឡេក៏បាន ដូច្នេះគាត់មិនរវីរវល់នឹងអត្តសញ្ញាណប័ណ្ណឡើយ។ ក្រសួងមហាផ្ទៃនិងស្នងការដ្ឋានតែងតែយកចិត្តទុកដាក់ក្នុងការជំរុញ ក្នុងការធ្វើអត្តសញ្ញាណប័ណ្ណនេះ ប៉ុន្តែមិនសូវមានប្រសិទ្ធភាពប៉ុន្មានទេ។ មកដល់ខែកក្កដាឆ្នាំ២០០៦នេះ ជាយុទ្ធនាការណ៍ដ៏ធំដែលក្រសួងមហាផ្ទៃបានកំណត់ថា ឆ្នាំ២០០៦នេះត្រូវតែធ្វើអោយហើយ ចំពោះប្រជាពលរដ្ឋដែលគ្រប់អាយុធ្វើអត្តសញ្ញាណប័ណ្ណ។ បច្ចុប្បន្ននេះយើងធ្វើបាន៥៨ម៉ឺន២ពាន់០៩៨នាក់ នៅសល់៤ម៉ឺនដែលយើងត្រូវពិនិត្យមើលថែមទៀត ព្រោះនៅក្នុងនោះយើងត្រូវដកចេញអ្នកដែលមិនអាចធ្វើអត្តសញ្ញាណប័ណ្ណបានដូចជាវិកលចារិក ជាប់ពន្ធនាគារ អ្នកទាំងនេះនៅព្រៃវែងយើងក៏មានច្រើនដែរ ខេត្តព្រៃវែងយើងមានជិត២ពាន់នាក់ អញ្ចឹងបច្ចុប្បន្ននេះយើងកំពុងតែយុទ្ធនាការឥឡូវនេះយើងកំពុងតែបំពាក់គ្រឿងឧបករណ៍សម្រាប់ធ្វើអត្តសញ្ញាណប័ណ្ណមកចំនួន៨គ្រឿង។

ពាក់ព័ន្ធនិងរឿងជនជាតិវៀតណាមខ្ញុំក៏មានយោបល់ខ្លះដែរ ខ្ញុំមិននិយាយពាក់ព័ន្ធដល់ការងារចុះឈ្មោះទេ តែខ្ញុំសូមជម្រាបអំពីជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង ដោយសារខ្ញុំមិនបានកាន់ឯកសារមកច្បាស់លាស់តែអំពីសកម្មភាពរបស់នគរបាល

បច្ចុប្បន្ន បច្ចុប្បន្ននេះយើងមានច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៍ ហើយក្រសួងមហាផ្ទៃក៏ដូចជាខេត្តក៏បានរៀបចំគណៈកម្មាធិការមួយស្តីពីការជំរឿននិងការគ្រប់គ្រងក្នុងបែងចែកវែតម្លែជនបរទេសដែលអន្តោប្រវេសន៍ ហើយជនអន្តោប្រវេសន៏នៅខេត្តព្រៃវែងនេះ បើនិយាយពីវៀតណាម គឺយើងបានធ្វើការស្រាវជ្រាវ អ្នកខ្លះនៅតាំងពីសម័យសង្គមរាស្ត្រនិយមអ្នកខ្លះក៏អត់ដែរ អញ្ចឹងគឺយើងបានស្រង់ទាំងអស់ទូទាំងខេត្ត បើចង់ដឹងច្បាស់ថា តួលេខប៉ុន្មាននោះខ្ញុំក៏មិនទាន់ដឹងច្បាស់លាស់ដែរ ប៉ុន្តែបច្ចុប្បន្ននេះខ្ញុំកំពុងតែដាក់កំលាំងស្រាវជ្រាវដើម្បីអោយបានច្បាស់ពីរឿងនេះ។ ហើយច្បាប់ក៏បានកំណត់ដែរថា ជនបរទេសដែលមិនមានសញ្ជាតិខ្មែរ មិនមែនតែវៀតណាមទេ ត្រូវធ្វើការបង់ពន្ធប៉ុន្មាននោះ គឺខាងក្រសួងមហាផ្ទៃកំពុងតែដំណើរការនិងពិនិត្យមើលអោយបានច្បាស់ពីបញ្ហានេះដែរ ថាអ្នកណាមានឡាំងតាយ មានលិខិតបទដ្ឋានមុនឆ្នាំ៧៥ប៉ុន្មាននាក់ អ្នកដែលអត់មានមុនឆ្នាំ៧៥ហើយមករស់នៅប្រទេសកម្ពុជានេះមានប៉ុន្មាននាក់ ហើយពីអាយុ១៨ឆ្នាំឡើងដែលត្រូវបង់ពន្ធជនរដ្ឋនោះមានប៉ុន្មាននាក់ អញ្ចឹងយើងធ្វើច្បាស់រឿងនេះអស់ហើយយើងនឹងសរុបរាយការណ៍ទៅក្រសួង អញ្ចឹងក្រសួងត្រូវអនុវត្តទៀតថា តើត្រូវបង់ពន្ធយ៉ាងម៉េច ?។ ហើយខ្ញុំក៏ទទួលស្គាល់ដែលអ្នកខ្លះមិនដឹងគាត់នៅតាំងពីឆ្នាំណាមាន មានលិខិតបទដ្ឋានទៅអ៊ុនតាក់គាត់បានធ្វើប័ណ្ណបោះឆ្នោតតាំងពីឆ្នាំ១៩៩៣មក អញ្ចឹងគាត់យកលិខិតបោះឆ្នោតនេះមកធ្វើបន្តបន្ទាប់។

លោក **ឈិត ផាត** ក្រុមប្រឹក្សាឃុំ ពាមរក៏ ស្រុកព្រែកកណ្តៀង លោកបានមានចំណាប់អារម្មណ៏ទាក់ទងទៅនឹងបញ្ហានៃការបោះឆ្នោតនៅថ្ងៃខាងមុខ។ ទី១ ពីការធ្វើការប្តូរប័ណ្ណបោះឆ្នោតចាស់មកធ្វើអត្តសញ្ញាណប័ណ្ណ ។ បញ្ហាគឺបងប្អូនដែលមានប័ណ្ណបោះឆ្នោតចាស់នោះហើយគាត់មិនមានអត្តសញ្ញាណប័ណ្ណ ហើយគាត់ធ្វើទំរង់១០១៨នោះវាក៏មិនបានគ្រប់៧គ្នានៅឡើយ ព្រោះខ្លះគាត់មិនមានរូបថតសម្រាប់ទៅធ្វើទំរង់១០១៨។ ហើយទី២ទៀតការបោះឆ្នោតយកអត្តសញ្ញាណប័ណ្ណយកទៅបោះឆ្នោត តាមយោបល់ខ្ញុំយល់ឃើញថា ធ្វើប័ណ្ណបោះឆ្នោតយើងមានលេខការិយាល័យ យើងមានលេខរៀង ដល់ពេលយើងយកអត្តសញ្ញាណប័ណ្ណទៅបោះឆ្នោតពេលនោះយើងមិនស្គាល់លេខការិយាល័យនិងលេខរៀងរបស់ខ្លួន តែបើយើងមានប័ណ្ណបោះឆ្នោតគឺថា កាលណាយើងចូលទៅភ្លាមគឺយើងដឹងថាលេខការិយាល័យរបស់យើងលេខប៉ុន្មាន ហើយមានលេខរៀងប៉ុន្មាន ហើយឥឡូវនេះដែលយើងអនុវត្តន៏គឺយកអត្តសញ្ញាណប័ណ្ណទៅបោះឆ្នោត ធ្វើអោយមានការពិបាកណាស់ស្វែងរកណាស់ចំពោះរឿងនេះ។

លោក **គឹម សុខុម** តំណាងលេខា ខមហ្វ្រែលប្រចាំខេត្តព្រៃវែង លោកបានលើកឡើងពីបញ្ហាខ្លះនៃដំណើរការចុះឈ្មោះបោះឆ្នោតក្នុងរយះកាលកន្លងមក គឺទី១មានការយឺតយ៉ាវម៉ោងពេលវេលា ដូចជានៅក្រុមប្រឹក្សាឃុំសង្កាត់ ជួនកាលគាត់លើសម៉ោងជួនកាលគាត់ខ្វះម៉ោងមិនទៅតាមកាលកំណត់របស់ គជប ។ ហើយបញ្ហាទី២គឺការខ្វះទំរង់១០១៨ និងខ្វះទំរង់១០២២។ ហើយបញ្ហាទី៣គឺ កម្មកររោងចក្រ ជាពិសេសនៅភ្នំពេញ គឺរោងចក្របង្ខំអោយអ្នកចុះឈ្មោះនៅតាមមូលដ្ឋាន ប៉ុន្តែការចុះនោះត្រូវមានប័ណ្ណបញ្ជាក់ថាអ្នកនោះបានចុះហើយ អញ្ចឹងគាត់មកដល់គាត់ត្រូវបង្ខំអោយក្រុមប្រឹក្សានិងស្មៀនឃុំត្រូវតែចុះប័ណ្ណព្រោះប័ណ្ណត្រូវយកទៅបង្ហាញគេវិញ នេះជាផលវិបាកចំពោះស្មៀនឃុំក្នុងការធ្វើ។

លោក **ឱក សេរី សោភក្តី** លោកបានមានប្រសាសន៏ថា ទាក់ទងនឹងការដែលប្រជុំនៅថ្នាក់ជាតិជាមួយម្ចាស់រោងចក្រ ជាមួយ គជប យើងបានដឹងថា ព្រោះរោងចក្រទាំងអស់ មិនមែនកម្មករទាំង៣សែននាក់ត្រូវទៅចុះឈ្មោះពិនិត្យបញ្ជីឈ្មោះទាំងអស់គ្នាទេ យើងចង់អោយរោងចក្រហ្នឹង នៅក្នុងបញ្ជីកម្មកររបស់គាត់ហ្នឹងមានក្រឡោងមួយទាក់ទងទៅនឹងរឿងបោះឆ្នោត អ្នកណាដែលបានចុះហើយនៅកន្លែងណានោះ សូមអោយគាត់ធ្វើអញ្ចឹង។ បានសេចក្តីថាអោយគាត់យកចិត្តទុកដាក់នៅក្នុងការបោះឆ្នោតរបស់កម្មកររបស់គាត់ហ្នឹង អោយចូលទៅក្នុងទិន្នន័យរបស់គាត់អោយបានច្បាស់លាស់ យើងធ្វើដូច្នេះដើម្បីងាយស្រួលថាតើអ្នកណាបានចុះហើយ

នៅកន្លែងណា ហើយអ្នកណាដែលមិនទាន់បានចុះ ដូច្នេះអ្នកដែលបានចុះហើយមិនបាច់ទៅទេ ហើយអ្នកដែលមិនទាន់បានចុះចាំទៅ ដូច្នេះរោងចក្រក៏ចំនេញ សហជីបក៏ស្រួល កម្មករក៏អាចដោះស្រាយបាន។

លោក **ស័ក្តិ ស៊ិនណារ៉ា** ក្រុមប្រឹក្សាស្រុកកំពង់លាវ មកពីគណបក្ស សម រង្ស៊ី លោកបានមានប្រសាសន៍ទាក់ទងនឹងកងកំលាំងប្រដាប់អាវុធប្រចាំ ខេត្តព្រៃវែង សូមអោយជួយធ្វើការបង្រ្កាបក្រុមបងតូចបងធំដែលតែងតែដើររករឿងឈ្លោះប្រកែកគ្នាតាមទីសាធារណៈ។

លោក **ឱក សេរីសោភ័ក្តិ** ចំពោះបញ្ហានេះលោកស្នងការរងមិនចាំបាច់ឆ្លើយទេ ព្រោះបញ្ហាមិនទាក់ទងទៅនិងរឿងបោះឆ្នោតទេ ។

លោក **ស៊ិន សារៈ** អភិបាលស្រុកពារាំង លោកបានលើកឡើងពីទំនាស់ដែលកើតមានឡើងមានច្រើននៅមូលដ្ឋាន ។ ទីមួយគឺនៅពេលយុទ្ធនាការឃោសនាបោះឆ្នោតឆ្នាំ២០០៣ មានគណបក្សខ្លះ ជាពិសេសគណបក្សហ៊្វុនស៊ិនប៉ិច គាត់បានប្រើប្រាស់រូបភាពឃោសនាដោយយកឆ្នោតវត្ថុទៅធ្វើការឃោសនាជាមួយប្រជាពលរដ្ឋនៅដំណាក់កាលចុងក្រោយ។ ហើយឆ្នោតវត្ថុនេះជាបញ្ហាមួយព្រោះខ្ញុំបើកមើលច្បាប់ទៅវាអត់មាននៅក្នុងច្បាប់បោះឆ្នោតរបស់យើងនេះ ក្នុងយុទ្ធនាការឃោសនា នេះជាការងារមួយដែលធ្វើអោយមានបញ្ហានៅមូលដ្ឋានដោយប្រជាពលរដ្ឋគាត់ផ្តល់សន្លឹកឆ្នោត ហើយខ្ញុំបានប្តឹងមកខាងលេខាធិការដ្ឋានគណៈកម្មាធិការបោះឆ្នោតហើយដោយនាំយកទាំងសន្លឹកឆ្នោតបានមកទាំងអស់ ប៉ុន្តែមិនឃើញមានការដោះស្រាយជាមួយនិងខាងខ្ញុំនៅឯស្រុក ។អញ្ចឹងគាត់យកសន្លឹកឆ្នោតវត្ថុរបស់គាត់ហ្នឹង ពេលដែលបោះឆ្នោតហើយ យកទៅផ្ទៀង ហើយនៅពេលយុទ្ធនាករឃោសនាបោះឆ្នោតហើយបើសិនជាគាត់ចេញមុននោះខ្ញុំមិនថាទេ។ នេះខ្ញុំសុំសួរថា ទី១ ខ្លាចគាត់យករូបភាពនេះ យកមកធ្វើនៅឆ្នាំខាងមុខនេះទៀត ដូច្នេះសូមអោយអស់លោកធ្វើការបកស្រាយអោយបានដឹងថា ច្បាប់នៃការចេញឆ្នោតហិរញ្ញវត្ថុនេះត្រូវមានច្បាប់អនុញ្ញាតិពីក្រសួងហិរញ្ញវត្ថុ ប៉ុន្តែថ្ងៃនោះខ្ញុំអត់ឃើញមានច្បាប់អនុញ្ញាតិអីទេ។ សន្លឹកឆ្នោតមួយដូរអោយគាត់ចេញប័ណ្ណ ដូចគាត់កសាងសមាជិកគាត់ទៅតាមរូបភាពសន្លឹកឆ្នោតនេះតែម្តង ហើយសន្លឹកឆ្នោតមួយចេញប័ណ្ណសំគាល់សមាជិកបក្សរបស់គាត់ភ្លាមអោយទៅអ្នកហ្នឹង នេះជាបញ្ហាមួយដែលខុសនិងច្បាប់នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។

ទី២គណបក្ស សម រង្ស៊ី នេះឃើញមានតែមួយទេ នៅទីស្នាក់ការគណបក្ស សម រង្ស៊ី នៅឃុំរការនេះលោកនិយាយថាវាមិនជាទូទៅទេសូមអភ័យទោស។ គឺគណបក្ស សម រង្ស៊ី មិនទាន់ដល់យុទ្ធនាការឃោសនាបោះឆ្នោតផង ស្នាក់ការរបស់ខ្លួនចាក់ផ្សាយនូវវេទិការសេរីសាធារណៈតាមឃោសនៈស័ព្ទ ធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលជាការខុសច្បាប់។

លោក **ឌឹក យ៉ុង** តំណាងគណបក្សហ្វុនស៊ិនប៉ិច ស្រុកសំរោង លោកបានមានប្រសាសន៍ទាក់ទងនឹងការបោះឆ្នោតកន្លងមក CEC រើសគណៈកម្មាធិការតាមការិយាល័យ តាមរយៈតែអ្នកកាន់អំណាច ដូចជាគ្រូបង្រៀន អំពីបញ្ហាការងារដូចជាការបិទប្រកាសល្ងាចម៉ោង៤ថ្ងៃអាទិត្យ ភ្ញាក់ឡើងម៉ោង៧ប្រលង អញ្ចឹងអ្នកដែលមានបំណងប្រឡងចូលរួមក្នុងគណៈកម្មាធិការរៀបចំការបោះឆ្នោតនៅតាមមូលដ្ឋានឃើញថា រៀបចំសំនុំឯកសារមិនទាន់ ហើយនៅពេលប្រជុំ ពេលរើសឃើញថាជាប់តែគ្រូបង្រៀនអំពីបញ្ហានេះ។

ហើយចំនុចមួយទៀត ខ្ញុំសូមសួរទៅខាងឧមប្រ៉េល ។ ឧមប្រ៉េលខ្ញុំឃើញថាតាមរយៈការបោះឆ្នោតពអាណត្តិនេះរើសតាមការិយាល័យមានតែបងប្អូនមេភូមិ បងប្អូនមេឃុំ នេះជាបញ្ហាការងាររបស់ឧមប្រ៉េលទេ តែខ្ញុំចង់សំនូមពរអោយគាត់បិទប្រកាសជាចំហរដើម្បីអោយបងប្អូនដែលគាត់ចង់ចូលរួមក្នុងការងារឧមប្រ៉េលនេះ។

លោក **ឡូញ ឡៃ** ក្រុមប្រឹក្សាឃុំកន្លង លោកលើកឡើងពីអាជ្ញាធរឃុំដែលបាននិយាយថាថ្ងៃចុះឈ្មោះគេថតប្រជាពលរដ្ឋទាំងអស់ដើម្បីបិទប្រវត្តិរូប ហើយអាជ្ញាធរឃុំបានប្រាប់ប្រជាពលរដ្ឋថា អ្នកណាបោះឆ្នោតអោយគណបក្សណាក៏ដឹងដែរ ព្រោះរូបថតដែលថតទៅនោះកិបជាប់និងសន្លឹកឆ្នោតគាត់បាននិយាយអញ្ចឹង បញ្ហានេះជាបញ្ហាមួយដ៏សំខាន់។

លោក **ស៊ឹម ស៊ីវ** គណបក្សប្រជាជន ឃុំព្រៃទទឹង លោកបានមានប្រសាសន៍ថាដើម្បីជៀសវាងនូវជំលោះនៃការឈ្លោះប្រកែកគ្នាទៅក្នុងមូលដ្ឋានរបស់លោក មុននឹងចាប់ផ្តើមធ្វើអ្វីមួយ ដូចជាការចុះឈ្មោះ និងពិនិត្យឈ្មោះបោះឆ្នោតហ្នឹង លោកតែងតែប្រមូលអោយតំណាងគណបក្សនយោបាយនានាទាំងអស់ចូលមកពិភាក្សាគ្នា ដើម្បីរកដំណោះស្រាយនឹងដើម្បីបង្ការនៅពេលចុះឈ្មោះនិងពិនិត្យឈ្មោះនៅពេលខាងមុខនោះ បើសិនជាមានបញ្ហាយើងតោងពិភាក្សាគ្នាដើម្បីដោះស្រាយ។ ឧទាហរណ៍ដូចជាករណីថាមេភូមិដើរចែកប័ណ្ណព័តមានអ្នកបោះឆ្នោតអោយតែបក្សពួកគាត់ ខ្ញុំបានជម្រាបថាមុននឹងយើងធ្វើអ្វីមួយយើងបានពិភាក្សាគ្នា ហើយខ្ញុំបានហៅតំណាងគណបក្សនោះទៅស្តីអោយនិងអោយគាត់ចុះកិច្ចសន្យាជាមួយខ្ញុំថ្ងៃក្រោយកុំអោយមានបញ្ហាហ្នឹងទៀត។

លោក **ថៃ ចំរើន** តំណាងគណបក្ស សម រង្ស៊ី លោកមានប្រសាសន៍ទាក់ទងនឹងរឿងប័ណ្ណព័តមាន ថាខាងលោកមេភូមិធ្វើការចែកតែបក្សពួកមែន ហើយបញ្ហាជនជាតិវៀតណាមបោះឆ្នោតបាន ថាជាការត្រឹមត្រូវ ព្រោះជនជាតិវៀតណាមក្លាយខ្លួនជាប្រជាពលរដ្ឋខ្មែររួចទៅហើយ ។ ហើយចំពោះរឿងការបោះឆ្នោតសូមអោយធ្វើការប្តូរការិយាល័យ ព្រោះការិយាល័យខ្លះមាននៅក្រោមផ្ទះមេភូមិដែលមាននៅស្រុកព្រះស្តេចឃុំជីកត្បូង ឃុំសេនារាជឧត្តម ។ ហើយនៅស្រុកមេសាងឃុំព្រៃទទឹងមានការិយាល័យ៣ទៀតក៏នៅក្នុងផ្ទះមេភូមិដែរ។ ដូច្នេះសូមអោយធ្វើការប្តូរការិយាល័យនោះអោយសមស្របជាការិយាល័យសាធារណៈ ។

លោក **ឱក សេរី សោភក្តិ** បានមានប្រសាសន៍ចំពោះរឿងការិយាល័យនៅក្រោមផ្ទះមេភូមិ ឬមួយនៅកន្លែងណាទៀតដែលជាផ្ទះឯកជននៅខេត្តឯទៀត១នោះ គឺយើងបានធ្វើការដោះស្រាយនៅថ្នាក់ជាតិហើយ សូមមិនអោយមានទៀតទេ ទៅតាមអ្វីដែលអាចធ្វើទៅបាន បើសិនជាខ្វះខាតខ្លាំងមែនទែនដោយសារបញ្ហារឿងលិចទឹក ឬមួយក៏អ្វីផ្សេងទៀតយើងគិតថាឆ្នាំក្រោយប្រហែលជាមិនមានទេ។ ហើយដល់បោះឆ្នោតមែនទែន គឺក្នុងករណីប្រធានសក្តិមិនអាចធ្វើយ៉ាងម៉េចបាន មានកន្លែងខ្លះត្រូវតែរកផ្ទះឯកជន ហើយប្រធាន PEC ត្រូវធ្វើការជួបប្រជុំជាបន្ទាន់ជាមួយគណបក្សនយោបាយទាំងអស់ដែលចូលរួមក្នុងការបោះឆ្នោតហើយសំរេចរួមនៅទីតាំងការិយាល័យបោះឆ្នោត។

លោក **ហួត ផាន** លោកបានធ្វើការឆ្លើយតបចំពោះបញ្ហាដែលសមាជិកអង្គប្រជុំបានលើកឡើងពាក់ព័ន្ធនឹងនីតិវិធីនៃការបោះឆ្នោត។ ទី១ លោក ឈិត ផានក្រុមប្រឹក្សាឃុំព្រៃកណ្តៀង លោកមានកង្វល់ពីការផ្លាស់ប្តូរការប្រើសប្រាស់ ការប្រើប្រាស់ប័ណ្ណបោះឆ្នោតមកប្រើអត្តសញ្ញាណប័ណ្ណនិងទំរង់១០១៨នេះ លោកមានការព្រួយបារម្ភខ្លាចប្រជាជនគាត់រកការិយាល័យបោះឆ្នោតមិនឃើញបញ្ហានេះលោកកុំព្រួយ ព្រោះនៅក្នុងពេលខាងមុខនេះ គជប នឹងរៀបចំធ្វើប័ណ្ណព័តមានមួយទៀត កាលពីមុនប័ណ្ណព័តមានសម្រាប់ទៅចុះឈ្មោះបោះឆ្នោត ដើម្បីអោយគាត់ដឹងថាឈ្មោះគាត់នៅការិយាល័យណាដើម្បីអោយគាត់ទៅផ្ទៀងផ្ទាត់មើលទិន្នន័យរបស់គាត់ក្នុងបញ្ជីបច្ចុប្បន្នភាពក្នុងបញ្ជី២០០៥ បញ្ជីចុងក្រោយនេះតើវាខុសយ៉ាងម៉េច ? អោយគាត់ធ្វើការកែតម្រូវ។ ប៉ុន្តែនៅពេលខាងមុខ គជប នឹងធ្វើប័ណ្ណព័តមានមួយជូនគ្រប់សាមីជនទាំងអស់ ដើម្បីប្រាប់គាត់ថាគាត់នៅការិយាល័យនេះ ហើយពេលទៅបោះឆ្នោតយើងកាន់ប័ណ្ណព័តមានហ្នឹង ដែលបញ្ជាក់ឈ្មោះ បញ្ជាក់ថ្ងៃខែឆ្នាំកំណើត បញ្ជាក់លេខការិយាល័យ បញ្ជាក់លេខរៀងរបស់គាត់ហ្នឹងភ្ជាប់ជាមួយ១០១៨ ភ្ជាប់ជាមួយអត្តសញ្ញាណប័ណ្ណគាត់កាន់ទៅបោះឆ្នោត។

បញ្ហាមួយទៀតរបស់លោក គីម សុខុម បញ្ហានេះជាបញ្ហាពិតត្រឹមត្រូវ ប៉ុន្តែបញ្ហាខ្វះទំរង់១០២២ និងទំរង់១០១៨ នេះ។ បញ្ហាខ្វះទំរង់១០២២ ដែលហៅថាប័ណ្ណចុះឈ្មោះបោះឆ្នោត កាលពេលចុះឈ្មោះនោះមានការខ្វះមែន គឺ គជប ផ្តល់អោយមិនទាន់មែន

ប៉ុន្តែមិនបណ្តាលអោយការចុះឈ្មោះនោះអសកម្មទេ គជប បានណែនាំយើងអោយបំពេញលើទំរង់១០២៣សិន។ ខ្ញុំបានជម្រាបទៅគ្រប់ឃុំទាំងអស់ថា បើឃុំណាដែលខ្វះ១០២២ នោះហើយដែលអសកម្ម មិនមែនមានន័យថា ឈប់ចុះឈ្មោះទេ គឺត្រូវតែនៅចុះឈ្មោះចុះចូលទៅ១០២៣សិន ហើយដល់ពេលដែលទំរង់១០២២ដែល គជប ផ្តល់មកអោយទើបយើងធ្វើការផ្ទេរឈ្មោះពី១០២៣ទៅ១០២២វិញ ដូច្នេះបញ្ហានេះមិនធ្វើអោយអសកម្មក្នុងការងារចុះឈ្មោះទេ។ បញ្ហាទំរង់១០១៨ គជប បានធ្វើការញែកជាពីរ។ ទី១ចំពោះអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចទៅហើយ ប៉ុន្តែគាត់គ្មានអត្តសញ្ញាណប័ណ្ណសម្រាប់កាន់ទៅបោះឆ្នោត ក្រុមប្រឹក្សាឃុំសម្រេចចេញ១០១៨ជូនគាត់ដែរ។ បញ្ហាទី២ បញ្ហាអ្នកដែលទៅចុះឈ្មោះថ្មី ហើយគ្មានអត្តសញ្ញាណប័ណ្ណ ឬគ្មានអ្វីសំអាងសម្រាប់កាន់ទៅចុះឈ្មោះ ក្រុមប្រឹក្សាឃុំស្មៀនឃុំចេញ១០១៨អោយដើម្បីកាន់ទៅចុះឈ្មោះបោះឆ្នោត។ ហើយក្នុងការចុះឈ្មោះនេះបើនរណាគ្មានរូបថត គជប អោយជំពាក់រូបថតបាន ធ្វើយ៉ាងណាអោយតែក្រុមប្រឹក្សាឃុំចេញ១០១៨អោយហើយ យកទៅអោយស្មៀនឃុំចុះចូលក្នុងបញ្ជីហើយ ហើយចាំដល់ថ្ងៃក្រោយ ក្រោយពីថ្ងៃចុះឈ្មោះរហូតដល់មុនថ្ងៃបោះឆ្នោត ចាំយករូបថតទៅបិត ហើយយកទៅអោយក្រុមប្រឹក្សាឃុំហត្ថលេខា ហើយយើងកាន់មួយសម្រាប់យកទៅបោះឆ្នោត។ ហើយថ្ងៃចេញ១០១៨ គឺចេញជូនរហូតដល់មុនថ្ងៃបោះឆ្នោតមួយថ្ងៃ។

ហើយបញ្ហាកម្មកររោងចក្រក៏មានការតឹងតែងដែរ សម្រាប់ចុះឈ្មោះបោះឆ្នោតហ្នឹង ដូច្នេះគេទៀមទារអោយអ្នកដែលនៅរោងចក្រហ្នឹងមានប័ណ្ណចុះឈ្មោះបោះឆ្នោតទាំងអស់គ្នាទោះជានៅទីណាក៏ដោយ ក៏ត្រូវអោយអ្នកដឹកនាំរោចក្រដឹងថា ខ្លួនមានកត្តាបព្វកិច្ចទៅចុះឈ្មោះបោះឆ្នោតនឹងទៅបោះឆ្នោតដែរ ដូច្នេះកម្មវិធីដែលរោងចក្រអោយមកនោះមានចែកជាកម្មវិធីថាថ្ងៃណាដែលអាចមកចុះឈ្មោះបោះឆ្នោតបាន។ ហើយក្នុងពេលដែលយើងខ្វះ១០២២ក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោតនោះគឺថា ខ្ញុំបានជម្រាបទៅលោកមេឃុំដែរថា បើសិនករណី១០២២កន្ទុយប័ណ្ណហ្នឹងមិនមានទេ សូមអោយលោកមេឃុំធ្វើយ៉ាងម៉េចចេញជាលិខិតមួយបញ្ជាក់ថាបានមកចុះឈ្មោះបោះឆ្នោតមែនហើយ ដើម្បីអោយកម្មករកាន់ទៅរោងចក្រវិញ។

ហើយបញ្ហាមួយទៀតរបស់លោក ស៊ិន សារៈ អភិបាលស្រុកពារាំង ដែលបានលើកឡើងពីការបោះឆ្នោត២០០៣នេះ រឿងនេះជារឿងពិតដែលកើតមាននៅស្រុកពារាំងកាលពីឆ្នាំ២០០៣ បញ្ហានេះខ្ញុំបានរាយការណ៍ជូន គជបដែរ។ ហើយការងារណាដែលយើងធ្វើទៅខុសនីតិវិធី គឺគណបក្សនានាមិនគួរធ្វើទេ បើច្បាប់ចែងថាម៉េចយើងត្រូវគោរពទាំងអស់គ្នាគោរពក្រមសីលធមិទាំងអស់គ្នាទើបយើងបានសេចក្តីសុខទាំងអស់គ្នា។

លោក **ថៃ ចំរើន** គណបក្ស សម រង្ស៊ី លោកបាននិយាយពីការចែកប័ណ្ណព័តមានកន្លងមកថា បញ្ហានេះមេភូមិមានការរអើងក្នុងការចែកប័ណ្ណ ដូច្នេះខ្ញុំសូមជម្រាបពីនីតិវិធីក្នុងការចែកប័ណ្ណព័តមាន។ ការចែកប័ណ្ណព័តមានក្នុងនីតិវិធីនៃការបោះឆ្នោតគឺមិនបានប្រគល់សិទ្ធអោយប្រធានភូមិទេ ដោយប័ណ្ណព័តមាននេះយកទៅអោយក្រុមប្រឹក្សាឃុំ ហើយក្រុមប្រឹក្សាឃុំ មេឃុំត្រូវចាត់ក្រុមប្រឹក្សាម្នាក់អោយទទួលរាប់រងចែកប័ណ្ណព័តមានហ្នឹង ដោយធ្វើកម្មវិធីចុះតាមភូមិទាំងអស់ ហើយមេភូមិមានភារៈកិច្ចតែមួយគត់គឺអញ្ជើញប្រជាជនអោយមកទទួលយកប័ណ្ណព័តមាន នៅសាលាឃុំ ឬនៅតាមទីប្រមូលផ្តុំតាមការណាត់របស់មេភូមិដែលអោយប្រជាជនមកទទួលយក។ ហើយចំពោះបញ្ហាមេភូមិមានការរអើងក្នុងការចែកប័ណ្ណព័តមានកាលជំនាន់នោះ យើងធ្វើការចែកទៅក្នុងរយៈពេលមួយខែ ហើយក្នុងរយៈពេលមួយខែចែកពាក់កណ្តាលខែហើយប័ណ្ណព័តមាននោះប្រជាជននៅតែមិនទៅយកនៅស្ទើរតែទាំងអស់ អញ្ចឹងយើងមានវិធានការណ៍ធ្វើម៉េចអោយប្រជាជនទទួលបានផង ខ្ញុំមានវិធានការណ៍មួយគឺថា អោយក្រុមប្រឹក្សាឃុំប្រគល់អោយទៅប្រធានភូមិ គឺវាខុសនីតិវិធី ប៉ុន្តែធ្វើម៉េចសម្រួលដល់ការចែកអោយអស់ អោយរហ័ស ពិព្រោះប័ណ្ណព័តមាននេះនៅសល់ច្រើនណាស់ព្រោះម្នាក់ហ្នឹងគាត់ដើរធ្វើមិនអស់ទេក្នុងមួយឃុំហ្នឹង អញ្ចឹងមានតែប្រធានភូមិជួយហើយកាលដែលយើងទៅរកប្រជាជន

នៅតាមផ្ទះនោះមិនងាយនឹងជួបទេ ដូច្នេះនីតិវិធីយើងមានតែមួយទេចែកអោយទៅប្រធានភូមិទៅព្រោះផ្ទះគាត់នៅនិងភូមិហ្នឹង ពេលគេនៅផ្ទះគាត់អាចយកទៅអោយទៅ។ ហើយកាលចែកអាចមានការលំអៀងខ្លះហើយ ព្រោះកាលចែកនេះមិនមែនដើរចែកបានគ្រប់ទាំងអស់គ្នាទេ ។ ហើយពាក់ព័ន្ធនឹងការចែកប័ណ្ណព័តមានចុះឈ្មោះបោះឆ្នោតនេះវាពាក់ព័ន្ធនិងការចែកប័ណ្ណព័តមាននៅក្នុងពេលខាងមុខខ្ញុំគិតថាថ្ងៃបោះឆ្នោតនៅពេលខាងមុខនឹងមាន CEC ជាអ្នកធ្វើហើយតែនៅតែមានការជំនួយពីអាជ្ញាធរដែនដីពីឃុំហើយនិងភូមិ។

បញ្ហាការិយាល័យនៅក្រោមផ្ទះប្រធានភូមិ គឺនីតិវិធីនៃការបោះឆ្នោតក៏បានកែលំអរហើយកន្លែងហ្នឹង បើសិននៅមានដូច្នេះខាងលេខាធិការដ្ឋាននឹងចុះទៅពិនិត្យជាក់ស្តែង ហើយបើឃើញថាវាអញ្ចឹងមែន យើងនឹងសូមធ្វើការដូរដើម្បីកុំអោយថ្ងៃបោះឆ្នោតមានបញ្ហា ដូចជាពាក់ព័ន្ធនិងការគៀបសង្កត់ផ្សេងៗ គឺយើងនឹងធ្វើការដូរហើយវាគ្មានបញ្ហាទេ។

លោក **ឱក សេរី សោភ័ក្តិ** លោកបានធ្វើការថ្លែងអំណរគុណចំពោះការបកស្រាយយ៉ាងក្បោះក្បាយរបស់ លោក ហួត ផានប្រធានលេខាធិការដ្ឋានខេត្តព្រៃវែង។ លោកក៏ធ្វើការបកស្រាយដែរចំពោះការធ្វើការជ្រើសរើសបុគ្គលិក PEC ហើយនិង CEC ព្រោះយើងជិតចូលមកដល់ហើយនៅថ្ងៃទី៣១ខែធ្នូនេះត្រូវរៀបចំការបោះឆ្នោតនៅខេត្ត ដូច្នេះហើយសូមអោយបងប្រធាន PEC ហ្នឹងធ្វើការប្រយ័ត្នប្រយែងព្រោះខេត្តច្រើនណាស់ដែលមានបញ្ហាចំពោះការជ្រើសរើសបុគ្គលិក PEC ហើយនិង CEC គឺបញ្ហាបងប្អូនខ្លួនឯង បញ្ហាបក្សពួកគឺមានច្រើនណាស់ហើយមិនមានតម្លាភាពទេទៅតាមនីតិវិធី។

ហើយរឿងបញ្ហាមេភូមិ។ មានមេភូមិខ្លះគាត់ធ្វើការចែកទៅមានការរើសអញ្ចឹងមែន ដូច្នេះបើមានព័តមានច្បាស់ថាឈ្មោះអីភូមិអីសូមបញ្ជូនមក យើងនឹងបញ្ជូនទៅក្រសួងមហាផ្ទៃដើម្បីធ្វើការតាមរឿងហ្នឹង និងអ្វីដែលក្រសួងនិង គជប មាននៅក្នុងដៃ។

ហើយបញ្ហាចុងក្រោយគឺរឿងដែលគួរអោយចាប់អារម្មណ៍បំផុតនោះគឺរឿងអនិជនវៀតណាម។ ព្រោះបើយើងធ្វើការគ្រប់គ្រងមិនបានទេ វាអាចឈានទៅដល់បញ្ហាផ្សេងៗទៀតជាបញ្ហានយោបាយ ដូច្នេះយើងនៅចាំហើយថាយើងគ្រប់គ្រងមិនបាននៅពេលដែលយើងធ្វើបាតុកម្មប្រឆាំងនិងស្ថានទូតថៃហើយនិងក្រុមហ៊ុនថៃនានា យើងត្រូវសងគេ៥០លានដុល្លា។ ដូច្នេះការគ្រប់គ្រងរឿងសញ្ជាតិជាបញ្ហាក្តៅគគុក ហើយជាពិសេសនៅក្នុងរដូវបោះឆ្នោតទៀត សូមអោយយើងប្រយ័ត្នប្រយែងនៅក្នុងព័តមាននេះ ហើយរឿងមានលុយកាក់មួយចំនួនអាចយកទៅធ្វើអត្តសញ្ញាណប័ណ្ណបាន ខ្ញុំទទួលស្គាល់ថាមានពិតប្រាកដ នៅភ្នំពេញក៏មាន នៅខេត្តឯទៀតៗក៏មាន ក៏ប៉ុន្តែមិនមានរហូតទៅដល់ថាអោយរាប់លាននាក់ដូចដែរការឃោសនាខ្លះ គឺមិនពិតទេ ដូច្នេះយើងត្រូវប្រយ័ត្នចំពោះតួលេខនិងសំដីដែលទាក់ទងទៅនឹងរឿងអនិជនវៀតណាម ពិព្រោះនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា នៅពេលដែលមានការជាប់ទាក់ទងទៅនឹងរឿងជនជាតិវៀតណាម សិតតែរឿងនយោបាយ និងពិបាកដោះស្រាយទាំងអស់សម្រាប់រាជរដ្ឋាភិបាលនិងសម្រាប់ប្រទេសជាតិទាំងមូល ហើយបើសិនយករឿងហ្នឹងមកដាក់ក្នុងការបោះឆ្នោតទៀត កាន់តែពិបាក ហើយយើងមិនអាចគ្រប់គ្រងយន្តការនៃការបោះឆ្នោតនេះបាន។ ដូច្នេះនេះជាការទទួលខុសត្រូវរបស់តួអង្គទាំងអស់ទាំងគណបក្សនយោបាយ ទាំងអាជ្ញាធរដែនដីដែលមានការខុសឆ្គងខ្លះក្នុងការចេញសំបុត្រអោយទៅអនិជនវៀតណាមនៅក្នុងពេលចុះឈ្មោះបោះឆ្នោត យើងដឹងថាមានតែមានតិចតួច តែយកទៅនិយាយថាមានរាប់ពាន់រាប់លាន នេះជាការនិយាយដែលមិនគួរនឹងធ្វើដែរ។

**លោក ខៀវ ជុំ** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា លោកមានសំនូមពរមួយទាក់ទងនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតខេត្តព្រៃវែង ចំពោះបញ្ហានៃការដោះស្រាយរាល់ពាក្យបណ្តឹងដែលខាង PEC ធ្វើការដោះស្រាយទោះគេព្រម ឬមិនព្រមក្តីសូមអោយផ្តល់ព័តមាននេះដល់ប្រជាពលរដ្ឋដែលជាអ្នកបោះឆ្នោតផង។

លោកស្រី **សំ ស៊ីថា** ប្រធានការិយាល័យ មន្ទីរកិច្ចការនារីខេត្តព្រៃវែង លោកស្រីបានសំដែងនូវចំណាប់អារម្មណ៏ដោយលើកឡើងពីបញ្ហារបស់ស្ត្រី ព្រោះបើគិតលើស្ត្រីទូទាំងប្រទេសមានចំនួនប្រហែល៥២ភាគរយនៃប្រជាពលរដ្ឋទូទៅ បានន័យថាបើយើង

និយាយពីការចូលរួមនៅក្នុងការបោះឆ្នោតស្ត្រីក៏មានសិទ្ធចូលរួមការបោះឆ្នោតដូចជាបុរស ។ ដោយមានសិទ្ធស្មើរគ្នាដូចនេះខ្ញុំសូមសំនូមពរថានៅពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ខាងមុខនេះ គួរតែដាក់បញ្ចូលស្ត្រីទៅតាមគណបក្សនិមួយៗអោយបានច្រើន ដោយអោយស្ត្រីមានអ្នកដឹកនាំជាស្ត្រីផងដែរនៅក្នុងស្នាក់ការឃុំនោះ ដើម្បីជួយដោះស្រាយលើបញ្ហារបស់ស្ត្រី ព្រោះមានតែស្ត្រីគ្នាឯងទេទើបយល់និងអាចជួយធ្វើការដោះស្រាយបាន។ ហើយបើអោយស្ត្រីឈរឈ្មោះ គួរតែអោយឈរអោយបានលេខរៀងបានគ្នាជាប់ផង កុំយកឈ្មោះគ្នាទៅដាក់នៅឈ្មោះចុងក្រោយគេ ធ្វើម៉េចនិងជាប់ ? ហើយក្នុងការជ្រើសរើសស្ត្រីដើម្បីអោយក្លាយទៅជាអ្នកដឹកនាំបានក៏ត្រូវតែអោយស្ត្រីនោះមានសមត្ថភាពក្នុងការដឹកនាំ មានសីលធម៌រស់នៅល្អ មានប្រពៃណីល្អ សមរម្យអោយគេគោរពរាប់អានថាជាថ្នាក់ដឹកនាំល្អផងដែរ នោះទើបស្ត្រីធ្វើហើយគ្នាមានតម្លៃ និងមានឥទ្ធិពលក្នុងការដឹកនាំផង។ ហើយស្ត្រីខ្លួនឯងក៏ត្រូវតែពង្រឹងសមត្ថភាពខ្លួនឯងអោយបានល្អប្រសើរ ថាយើងធ្វើអ្វីខ្លះដើម្បីស្ត្រី ដើម្បីប្រទេសជាតិ ដើម្បីការអភិវឌ្ឍន៍អោយរីកចំរើន កាន់តែប្រសើរឡើងនិងកាន់តែមាននិរន្តន៍ភាពតទៅទៀត។ ទន្ទឹមនិងនេះស្ត្រីក៏ត្រូវមានសិទ្ធ សិទ្ធតស៊ូមតិយោបល់ សិទ្ធក្នុងការធ្វើសេចក្តីសម្រេចចិត្ត សិទ្ធក្នុងការចូលរួមនយោបាយ សិទ្ធក្នុងការចូលរួមលើគ្រប់វិស័យទាំងអស់ក្នុងសង្គមដែលមានការអនុវត្តន៍នាពេលបច្ចុប្បន្ននេះ ដើម្បីអោយមានការរីកចំរើន។

លោក **ហង្ស យ៉ុន** ជំទប់ទី១ ស្រុកកំពង់លាវ លោកបានបង្ហាញជូននូវភាពមិនប្រក្រតីនៅក្នុងពេលបោះឆ្នោត តាមការដែលលោកសង្កេតឃើញពីការបោះឆ្នោតតំណាងរាស្ត្រ និងក្រុមប្រឹក្សាឃុំ បច្ចុប្បន្នហ្នឹងប្រធានភូមិគាត់បានចូលរួមនៅក្នុងការបណ្តុះបណ្តាលពីច្បាប់នីតិវិធី ក្រុមប្រឹក្សាខ្ញុំហ្នឹងមានអង្គការខ្លះហៅប្រធានភូមិទៅរៀន ក៏គាត់នៅតែរំលោភទៅលើនីតិវិធីដដែរ។ ការរំលោភទៅលើនីតិវិធីនោះគឺ កាលនោះគេបានណែនាំថាដល់ពេលបោះឆ្នោតហ្នឹង កុំអោយប្រធានភូមិនិងក្រុមប្រឹក្សាឃុំគាត់ទៅឈរនៅមាត់ទ្វានៅពេលបោះឆ្នោតហ្នឹង តែនេះខ្ញុំឃើញមាន ហើយខ្ញុំដើរទៅមើល ខ្លះគាត់ដឹងគាត់ដើរចេញទៅ ខ្លះគាត់ធ្វើមិនឃើញនៅឈរដដែរ។ ទីពីរ សូមអោយលោកប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត ធ្វើម៉េចជួយចេញច្បាប់អោយបានតឹងរឹង ឬហៅប្រធានភូមិទៅបណ្តុះបណ្តាលបន្ថែមបើមិនអញ្ចឹងទេគាត់នៅតែអនុវត្តន៍ខុសដដែរ។

លោក **ឱក សេរី សោភក្តិ** លោកបានមានប្រសាសន៍ថាយើងបានធ្វើការជាមួយក្រសួងមហាផ្ទៃនិងគ្រប់ខេត្តទាំងអស់ដែលយើងបានឆ្លងកាត់ជាមួយនិងអភិបាលស្រុកដែលអញ្ជើញមកក្នុងឧបសែលប្រ៉មជាហូរហែរនៅខេត្តទាំងប៉ុន្មាននោះ ហើយធ្វើការជាមួយ គជប យើងបានមកដល់ចំនុចដោះស្រាយថា ខាងក្រសួងលោកនឹងចេញសេចក្តីណែនាំនៅក្នុងរឿងនេះ គឺនៅពេលបោះឆ្នោតខាងមុខមិនអោយមានវត្តមានអាជ្ញាធរមូលដ្ឋាននៅជុំវិញការិយាល័យបោះឆ្នោតទៀតទេ។ ដោយសាររឿងនេះហើយទើបបានជា គជប បន្ថែមមនុស្សម្នាក់ទៀតនៅក្រៅការិយាល័យបោះឆ្នោត ដើម្បីអោយជួយរកឈ្មោះអោយប្រជាពលរដ្ឋដែលពិបាករកឈ្មោះ ដើម្បីកុំអោយអាជ្ញាធរមូលដ្ឋានហ្នឹងបោះឆ្នោតហើយនៅជុំវិញស្ថានីយ៍ទៀតថាជួយរកឈ្មោះទៀត។

លោក **យិន សារិន** គណបក្ស សម រង្ស៊ី ស្រុកកំពង់ត្របែក ខេត្តព្រៃវែង បានសំដែងនូវការព្រួយបារម្ភថានៅមុនពេលបោះឆ្នោតក្រុមប្រឹក្សាឃុំរមា គាត់ថាការបោះឆ្នោតបើពីមុន គណបក្សហ៊្វុន ស៊ិនប៉ិច មិនអាចឡើងជាក្រុមប្រឹក្សាឃុំលើសពី ៣ទេ មានតែថយចុះ អញ្ចឹង លោក បានសំនូមពរអោយ គជប ផ្តល់ក្តីសង្ឃឹមដល់ លោក ជាពលរដ្ឋផង ។ ហើយរចនាសម្ព័ន្ធរបស់ គជប ដែល លោក ចង់អោយធ្វើការកែប្រែនោះ គឺ ធ្វើយ៉ាងណាអោយ លោក មានសង្ឃឹមផងក្នុងការបោះឆ្នោតនេះ។

លោក **ឌុល ឆុន** ជំទប់ទី២ គណបក្ស សមរង្ស៊ី ស្រុកកំពង់លាវ បានលើកឡើង ២ចំនុច ទី១ ទាក់ទងនឹងអាជ្ញាធរមូលដ្ឋាននិងគណៈកម្មាធិការខេត្តទៅឈរនៅមុខការិយាល័យបោះឆ្នោត ។ ទី២ ទាក់ទងទៅនឹងការបោះឆ្នោតឆ្នាំ២០០៣ព្រឹទ្ធសភាគេមិនទាន់ទាំងរាប់សន្លឹកឆ្នោតផង ស្រាប់តែប្រកាសកៅអីរួចទៅហើយ ដែលកាលនោះគណបក្សប្រឆាំងក៏ដូចជាអង្គការសង្គមស៊ីវិលក៏បាន

ប្រឆាំងថាកុំអាលធ្វើអញ្ចឹងអី  ដូច្នេះយើងត្រូវគិតឡើងវិញ  ខ្ញុំខ្លាចបញ្ហានេះកើតមាននៅក្នុងឆ្នាំ២០០៧ទៀត។  ហើយទាក់ទងនឹងទង្វើលថ្មី១នេះគឺមានគណបក្សមួយគេដើរថតរូបថតប្រជាជន ហើយបង្ខំអោយពាក់អាវគណបក្ស ដល់ខ្ញុំទៅជួបសួរគាត់ថាម៉េចបានជាបង្ខំអោយប្រជាពលរដ្ឋពាក់អាវគណបក្ស គាត់ឆ្លើយថា គណបក្សគាត់ស្រេចតែគាត់ ។ ហើយមួយទៀតប្រជាពលរដ្ឋគាត់គិតថា ទាល់តែទៅថតនិងគេ បានគេអោយអំណោយ ស្រាប់តែទៅថតគេអត់ថតអោយទេ គេថាមិនមែនគណបក្សហ្នឹងគេមិនអោយទេ។

លោក **ជាង សូផាត** ជំទប់ទី១ ស្រុកកំចាយមាស លោកបានធ្វើការបកស្រាយពីកង្វល់ទៅលើការបោះឆ្នោតនៅក្នុងឆ្នាំ២០០៧ខាងមុខនេះ។ លោកបានមានប្រសាសន៏ថា មុននឹងចូលដល់យុទ្ធនាការឃោសនាចុះឈ្មោះបោះឆ្នោតយើងត្រូវធ្វើការចែកប័ណ្ណព័តមាន ហើយការចែកប័ណ្ណនេះយើងបានរៀបចេញជាកាលវិភាគមួយ នៅសៀងខាងមាន ១៣ភូមិ ហើយយើងរៀបកាលវិភាគតែ១៣ថ្ងៃទេ ការចែកចាយប័ណ្ណព័តមាននេះឯង ដោយមានមតិណែនាំចេញពី គជប ហើយមួយថ្ងៃយើងសាកល្បងធ្វើមួយភូមិធ្វើអត់ចេញ។ ទី១គឺប្រជាពលរដ្ឋគាត់មិននៅផ្ទះ ដូច្នេះការចែកប័ណ្ណព័តមាននោះគឺមិនដល់ដៃទេ ហើយពេលនោះឃើញថាមានមន្ត្រីក្រុមប្រឹក្សាឃុំម្នាក់ដែលទទួលខុសត្រូវនៅក្នុងរឿងនេះ តែការចែកនោះវាមិនបានដល់ដៃ មានបញ្ញើរខ្លះ និងដល់ដៃខ្លះ ខ្ញុំជឿថាវាមានបញ្ហាហ្នឹង ។ ហើយការធ្វើបែបនេះគឺមិនអាចចែកអោយបានអស់ទេ ខ្ញុំក៏បានផ្តល់យោបល់មួយអោយមន្ត្រីទទួលខុសត្រូវជូនព័តមានមក គជប ខេត្តដើម្បីសូមធ្វើការពន្យារអោយបានឆ្ងាយបន្តិចដល់ធ្វើទៅយើងបាន៧០ទៅ៨០ភាគរយដល់ដៃ។

ហើយជំហានទី២ គឺរយៈពេល២៤ថ្ងៃនៃការចុះឈ្មោះបោះឆ្នោត នៅក្នុងឃុំសៀងខាងយើងខ្ញុំ គ្រប់គណបក្សនយោបាយបានចូលរួមទាំងអស់គ្នាដោយគ្មានបញ្ហាអីកើតឡើងទេ។ ក្នុងយុទ្ធនាការចាប់ផ្តើមភ្លាមមានគណបក្ស ហ៊្វុនស៊ិនប៉ិចបានមកសំនូមពរខ្ញុំថាគួរតែអោយគណបក្សទាំងអស់នៅក្នុងឃុំសៀងខាងដើរប្រមូលសមាជិករបស់ខ្លួនមកចុះឈ្មោះ  ខ្ញុំថារឿងទាំងអស់នេះសូមលោកទៅពាក់ព័ន្ធជាមួយមន្ត្រីចុះឈ្មោះ ហើយខ្ញុំក៏បានណែនាំគាត់ថា បញ្ហានេះដូចជាគ្មានច្បាប់ទេ ព្រោះតួនាទីថ្ងៃនោះមានតែមន្ត្រីចុះឈ្មោះរបស់ គជប និងមេភូមិទេ ហើយយើងមាននាមត្រឹមតែអ្នកសង្កេតការណ៍ យើងសង្កេតការណ៍មើលទៅ ។ ហើយរឿងមួយទៀតគឺមានគណបក្សមួយបាននាំនារីម្នាក់អាយុប្រហែល២៣-២៤ឆ្នាំ ប៉ុន្តែឯកសារគាត់មិនត្រឹមត្រូវ ដោយគណបក្សនោះយកមកអោយខ្ញុំពិនិត្យមើលព្រោះខ្ញុំជាអ្នកទទួលខុសត្រូវរួម ខ្ញុំគ្រាន់តែពិនិត្យមើលឆ្នាំកំណើតរបស់គាត់១៩៩៩០ ចំនួនឆ្នាំនោះគឺខុសហើយ បើខ្ញុំលុបអោយទោះលុបលេខសូន្យខាងក្រោយចេញក៏នៅតែមិនដល់អាយុ អញ្ចឹងហើយខ្ញុំមិនអាចធ្វើជូនទេ ត្រូវអោយគាត់កែតម្រូវឯកសារគាត់ឡើងវិញ នេះជាកំហុសរបស់អ្នកណា ? មិនមែនកំហុសរបស់ប៉ូលីសទេ គឺកំហុសរបស់គាត់ ដែលគាត់មិនយល់ទាក់ទងទៅនឹងចំណេះដឹង។ ហើយសំនូមពររបស់ខ្ញុំ គឺទី១ ទាក់ទងទៅលោកស្នងការ ពីរឿងអត្តសញ្ញាណប័ណ្ណ។ អត្តសញ្ញាណប័ណ្ណនេះខ្លះបានថតរួចទៅហើយតែមិនទាន់ឃើញធ្លាក់ទៅវិញទេ ប៉ុន្តែឯកសារដែលយើងធ្វើទាក់ទងទៅនិងទំរង់១០១៨ យកតាមចម្លើយផ្ទាល់មាត់ តែបើសិនជាអត្តសញ្ញាណប័ណ្ណធ្លាក់មកវាខុសពីទំរង់១០១៨របស់ គជប ដែលចេញអោយនោះប្រហែលជាមិនបានបោះឆ្នោតទេ នេះតាមដែរខ្ញុំយល់ ដូច្នេះខ្ញុំសូមសំនូមពរថាអោយចេញអត្តសញ្ញាណប័ណ្ណនេះអោយបានទាន់ពេលវេលា។ ហើយឆ្នាំនេះកំណើនប្រជាពលរដ្ឋដែលចុះឈ្មោះនៅក្នុងមូលដ្ឋានខ្ញុំមានច្រើន ដែលការពិតនោះភាគច្រើនគឺប្រជាពលរដ្ឋយើងខ្លះទើបតែមានអាយុ១៤ទៅ១៥ឆ្នាំទេ តែឪពុកម្តាយបានបន្ថែមអាយុដល់១៨ឆ្នាំ ដើម្បីអោយពួកគាត់មានអាយុគ្រប់អាចទៅធ្វើការនៅតាមរោងចក្របាន ហើយរឿងទាំងអស់នេះវាជាប់ទាក់ទងទៅនឹងជីវភាព។

លោក **ស៊ីន សារៈ** លោកបានលើកឡើងពីរឿងប្រធានភូមិ ក្នុងនាមលោកជាអាជ្ញាធរស្រុក លោកក៏មានកង្វល់ដែរពីបញ្ហានេះ។ ចំពោះពាក្យថាមិនអោយ មេភូមិ មេឃុំ ក្រុមប្រឹក្សាឃុំ ឬក៏អ្នកមានអំណាច ចូលទៅក្នុងការិយាល័យបោះឆ្នោតនោះខ្ញុំមិនឯកភាពទេ ព្រោះមេភូមិ មេឃុំ និង ប្រជាពលរដ្ឋទាំងអស់សិតតែមានសិទ្ធចូលទៅការិយាល័យបោះឆ្នោតទាំងអស់ដើម្បីធ្វើការ

បោះឆ្នោត ហើយដើម្បីជៀសវាងនូវបញ្ហាកើតឡើងនោះ សូមអោយពួកគាត់បានបោះឆ្នោតមុនគេ តែបោះឆ្នោតហើយគាត់ទៅផ្ទះអស់ហើយ គាត់មិននៅទីនោះទៀតទេ។

លោក **ស័ក្តិ ស៊ិនណារ៉ា** ក្រុមប្រឹក្សាស្រុកកំពង់លាវ គណបក្ស សម រង្ស៊ី លោកបានសំនូមពរទៅកាន់គណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្តសូមអោយធ្វើការគោរពពេលវេលា  ព្រោះមានន្ត្រីចុះឈ្មោះបោះឆ្នោតខ្លះគាត់មិនគោរពពេលវេលានៃម៉ោងធ្វើការគឺការងារដែលគាត់ជាអ្នកចុះឈ្មោះបោះឆ្នោតនោះគាត់ធ្វើការបិទមុនពេលកំណត់ ហើយប្រជាពលរដ្ឋគាត់ទៅទៅចុះឈ្មោះគាត់ថា បិទហើយចាំព្រឹកស្អែកចាំមកចុះទៀត។ ធ្វើអោយប្រជាពលរដ្ឋគាត់មានការពិបាកក្នុងការធ្វើដំណើរទៅចុះឈ្មោះម្តងទៀត ឬគាត់មិនទៅចុះឈ្មោះតែម្តង។

លោក **ឌុល ឆុន** គណបក្ស សម រង្ស៊ី លោកបានមានប្រសាសន៍ថា បើមេភូមិ និងមេឃុំទៅកន្លែងបោះឆ្នោត ហើយទៅតែបោះឆ្នោតមិនជាអ្វីទេ តែទៅនោះ គឺទៅឈរនៅរារេខាងមុខហ្នឹងមិនទៅវិញទេ ដល់ លោក ទៅប្រាប់គាត់អោយទៅ ស្រាប់តែថាតឹងម្ល៉េះ ខ្ញុំថាច្បាប់គេអោយធ្វើអញ្ចឹង ហើយថ្ងៃនោះមានទាំងគណៈកម្មាធិការខេត្តផងដែរដែលទៅឈរនៅទីនោះ។

លោក **ឈិត ផាត** ឃុំព្រែកកណ្តៀង លោកបានមានប្រសាសន៍ទាក់ទងនិងប្រជាពលរដ្ឋដែលមកចុះឈ្មោះច្រើន តែធ្វើការកែឈ្មោះគឺបានតិចណាស់ ដូច្នេះហើយខ្ញុំចង់សួរថា តើ CEC ដែលជ្រើសរើសថ្មីជាមនុស្សនៅក្នុងភូមិឬជាអ្នកដែលធ្លាប់ធ្វើ CEC ក្នុងពេលកន្លងមក ហើយបើធ្លាប់ធ្វើ CEC កន្លងមកគាត់ធ្លាប់ដឹងថាប្រជាពលរដ្ឋនេះ មានមុខហ្នឹង ហើយគាត់ឈ្មោះហ្នឹងមែនតែគាត់ខុសថ្ងៃខែឆ្នាំកំណើតគាត់បន្តិចបន្តួច តើយើងអាចអោយគាត់បោះឆ្នោតបានដែរឬទេ ? ពិព្រោះវាមានការពាក់ព័ន្ធច្រើននៅក្នុងបញ្ហានេះ។ ហើយសំនូមពរមួយទៀតដល់ លោកលេខាធិការរៀបចំការបោះឆ្នោត ធ្វើម៉េចបញ្ជីតំបូងនិងបញ្ជីចុងក្រោយធ្វើយ៉ាងម៉េចអោយបានត្រឹមត្រូវដូចគ្នា ព្រោះពីឆ្នាំ២០០៣មក២០០៧ បញ្ជីតំបូងចេញមកប៉ុណ្ណេះ តែដល់បញ្ជីចុងក្រោយដល់បោះឆ្នោតទៅថាអត់មានឈ្មោះ ហើយគាត់មានទំរង់១០១៨និងប័ណ្ណបោះឆ្នោតហើយទៅបោះឆ្នោតតែអត់មានឈ្មោះបោះឆ្នោត ដូច្នេះសូមអោយលេខាធិការធ្វើម៉េចសំរង់បញ្ជីបោះឆ្នោតហ្នឹងអោយបានត្រឹមត្រូវតាមបញ្ជីតំបុងហើយនិងបញ្ជីចុងក្រោយ។

លោក **ឱក សេរីសោភក្តិ** បានមានប្រសាសន៍ថា នៅក្នុងរឿងនេះបានធ្វើការជាមួយ គជប ថាបើមានខុសឈ្មោះបន្តិចបន្តួចថ្ងៃខែឆ្នាំកំណើតអត់អីទេ បោះឆ្នោតបាន។ បញ្ហាបើតាមខ្ញុំបាទយល់គឺ ដោយសារអត្តសញ្ញាណប័ណ្ណមិនទាន់ចេញ ហើយយើងប្រើទំរង់១០១៨នៅពេលដែលយើងចុះឈ្មោះបោះឆ្នោត បើសិនជាយើងខុសគ្នាបន្តិចបន្តួច ដល់ពេលអត្តសញ្ញាណប័ណ្ណចេញមកខុសគ្នាពីទំរង់១០១៨នៅពេលដែលយើងចុះឈ្មោះបោះឆ្នោត អត់អីទេ យើងប្រើអត្តសញ្ញាណប័ណ្ណបាន ព្រោះអត្តសញ្ញាណប័ណ្ណជាឯកសារផ្លូវការ។ ប៉ុន្តែបញ្ហាបារម្ភគឺថា នៅពេលគាត់ធ្វើ១០១៨នោះគឺចុះឈ្មោះផ្សេង ដល់អោយឈ្មោះទៅធ្វើអត្តសញ្ញាណប័ណ្ណឈ្មោះផ្សេងគ្នាទៀតធ្វើអោយខុសគ្នាដាច់តែម្តងឈ្មោះពីរហ្នឹង អញ្ចឹងតោងតែប្រយ័ត្នអោយមែនទែនពីបញ្ហានេះ។

លោក **ហួត ផាន** លោកបានធ្វើការដោះស្រាយទៅលើមតិរបស់វាគ្មិនមួយចំនួនដែលបានលើកឡើងមានដូចជា :

ទី១ លោកលើកឡើងពីសំនួររបស់លោក ខៀវ ជុំ ដែលលោកបានលើកឡើងថា នៅក្នុងរបាយការណ៍របស់ខ្ញុំមានការដោះស្រាយនូវបញ្ហាទំនាស់នានា តែមិនឃើញខ្ញុំលើកឡើង។ ខ្ញុំសូមបញ្ជាក់ប្រាប់ទៅលោកថា បញ្ហាទំនាស់នេះជាទំនាស់ជាប្រចាំថ្ងៃក្នុងការចុះឈ្មោះក្តី ក្នុងការបោះឆ្នោតក្តី ឧទាហរណ៍ថា ប្រធានភូមិគាត់ម៉ោង៨ហើយមិនទាន់មកដល់ទេ អញ្ចឹងគេទូរស័ព្ទមកភ្លាម យើងដោះស្រាយភ្លាមដោយការសម្របសម្រួលគ្នាទៅវិញទៅមក។ ហើយឧទាហរណ៍ដូចជានៅក្នុងពេលបោះឆ្នោតគណបក្សមួយចងបារដាទទឹងផ្លូវគេប្តឹងមកភ្លាមយើងអោយគេដកភ្លាម។ ហើយការប្តឹងនេះមិនមានជាលាយល័ក្ខអក្សរទេ គឺប្តឹងតាមមាត់ទទេរទេ តែយើងដោះស្រាយភ្លាមដើម្បីកុំអោយមានបញ្ហាធំកើតឡើង។ ហើយដើម្បីកាត់បន្ថយនូវរាល់បញ្ហាទំនាស់ទាំងអស់ យើងក៏បានអញ្ជើញគ្រប់

គណបក្សនយោបាយទាំងអស់ ដើម្បីមកណែនាំប្រាប់មុន ដូច្នេះបញ្ហាទំនាស់ក៏មិនអីទេ តែបើយើងបានធ្វើ គជប សម្រេចថាធ្វើប៉ុន្តែគណបក្សនិមួយៗមិនដឹងនោះវាអាចកើតមានបញ្ហាដែរ ព្រោះកន្លងមកធ្លាប់មាន ដូច្នេះហើយទើបនៅពេលយើងសម្រេចថាធ្វើអ្វីមួយនោះយើងតែងតែប្រជុំពិភាក្សាគ្នាអោយដឹងមុនថា ថ្ងៃណាត្រូវធ្វើអី ថ្ងៃណាត្រូវធ្វើអីអោយស្រេចជាមុន។

ទី២ បញ្ហាលោក ហង្ស យ៉ុន ដែលលោកបានលើកពីបញ្ហាប្រធានភូមិនៅការិយាល័យបោះឆ្នោត។ រឿងនេះ គជប និងក្រសួងមហាផ្ទៃបានសម្រេចរួចមកហើយ និងចេញនៅក្នុងនីតិវិធីរួចមកហើយថា ប្រធានភូមិ អាជ្ញាធរ អនុប្រធានភូមិទាំងអស់ពេលទៅបោះឆ្នោតហើយសូមមេត្តាអញ្ជើញចេញ នេះគឺនីតិវិធីបានចេញរួចហើយ។

ទី៣ បញ្ហាលោក ឌុល ឆុន បានលើកថាបោះឆ្នោតចប់ហើយ មិនទាន់ទាំងប្រកាសលទ្ធផលការបោះឆ្នោតផង មានអ្នកប្រកាសថាឈ្នះហើយនោះវាមិនជាផ្លូវការទេ ព្រោះអ្នកបច្ចេកទេសមិនទាន់បានប្រកាសនៅឡើយ។

ទី៤ បញ្ហាលោក ជាង សូផាត លោកបានលើកឡើងថាប្រធានភូមិគាត់មកចុះឈ្មោះមិនទាន់នោះ ជួនកាលអាចគាត់មានធុរៈបន្តិចបន្តួចគាត់មកមិនទាន់ រឿងនេះយើងបានសម្របសម្រួលគ្នាហើយ ហើយពេលខ្លះគាត់ក៏ធ្វើការលើសម៉ោងដែរ ។ ហើយចំពោះបញ្ហាធ្វើអត្តសញ្ញាណប័ណ្ណថ្មី ព្រោះប្រជាពលរដ្ឋគាត់បានទៅធ្វើអត្តសញ្ញាណប័ណ្ណមុនពីរបីខែហើយ ប៉ុន្តែអត្តសញ្ញាណប័ណ្ណគាត់មិនទាន់ធ្លាក់មកហើយកាត់ទៅធ្វើការចុះឈ្មោះបោះឆ្នោត ហើយអត្តសញ្ញាណប័ណ្ណជួនកាលពេលធ្លាក់មកអាចខុសជាមួយបញ្ជីបោះឆ្នោតនេះជាការពិត ហើយបញ្ហានេះខ្ញុំបានជម្រាបទៅក្រុមប្រឹក្សាឃុំអស់ហើយថា អោយគាត់ចេញ១០១៨អោយហើយទៅ ពិព្រោះអត្តសញ្ញាណប័ណ្ណពេលដែលគាត់ធ្វើនោះ តើឈ្មោះហ្នឹង ថ្ងៃខែនោះត្រូវជាមួយបញ្ជីបោះឆ្នោតឬអត់ ហើយភាគច្រើនគឺអត់ត្រូវ។ ហើយបើសិនជាអត្តសញ្ញាណប័ណ្ណនោះធ្លាក់មកមុនថ្ងៃបោះឆ្នោត បើឈ្មោះនោះត្រូវនិងបញ្ជីបោះឆ្នោតនោះយើងកាន់អត្តសញ្ញាណប័ណ្ណទៅបោះឆ្នោតបាន តែបើមិនត្រូវទេ យើងកាន់១០១៨ទៅបោះឆ្នោតដដែរ។

ទី៥ បញ្ហាដែលមានខុសឈ្មោះបន្តិចបន្តួច គឺការបោះឆ្នោតអាចអនុញ្ញាតិអោយធ្វើការបោះឆ្នោតបាន ប៉ុន្តែកុំអោយមានកំហុសច្រើនពេក។

លោក **ឡារី ស្ត្រេន្ទ** លោកបានថ្លែងនូវអំណរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់វាគ្មិនទាំងអស់ដែលបានមកចូលរួមប្រជុំនៅក្នុងខប់សែលប្រ៊មថ្ងៃនេះ។ លោកក៏បានលើកឡើងនូវចំនុចសំខាន់២ថា ហេតុអ្វីបានជាវិទ្យាស្ថាន CDRI ក៏ដូចជាកម្មវិធីខប់សែលបានផ្តោតសំខាន់ទៅលើភាពត្រឹមត្រូវនិងការចែករំលែកព័តមានទាំងឡាយនៅក្នុងការបោះឆ្នោតទាំងអស់នេះ។ ចំនុចមួយសំខាន់គឺជាការដែលយើងធានាបាននូវការចែកចាយព័តមាន អោយបានត្រឹមត្រូវច្បាស់លាស់នេះគឺជាជំហាននៅក្នុងការអនុវត្តន៍ដើម្បីអោយការបោះឆ្នោតមានតម្លាភាពនិងទទួលយកបាន។ ចំនុចមួយទៀត ខ្ញុំសូមចែករំលែកនូវបទពិសោធន៍មួយ ក្នុងនាមខ្ញុំជាជនបរទេសខ្ញុំបានរៀនសូត្រនូវបទពិសោធន៍ជាច្រើន ទាក់ទងទៅនឹងការទទួលបាននូវលទ្ធិប្រជាធិតេយ្យមួយដ៏រឹងមាំនិងមានគោលនយោបាយមួយដែលចាស់ចិត្តចាស់គំនិត ហើយដែលយើងត្រូវការពេលវេលាជាច្រើននឹងត្រូវការធ្វើជាបណ្តើរៗ។ ហើយការធានាអោយបាននូវធម្មនុញ្ញប្រក្របទៅដោយលទិប្រជាធិតេយ្យនេះបានដោយសារតែការអញ្ជើញចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលមាន។

លោក **ឱក សេរី សោភក្តិ** លោកបានមានប្រសាសន៍ថា លោកមានការរីករាយណាស់ដែលអស់លោក លោកស្រី ជាវាគ្មិនទាំងអស់បានបញ្ចេញមតិប្រកបទៅដោយការគោរពគ្នាទៅវិញទៅមក ដោយសេចក្តីថ្លៃថ្នូរដាក់គ្នា តាំងនាមអោយវិទ្យាស្ថាន CDRI និងក្រុមការងារទាំងអស់ លោកសូមបួងសួងអោយព្រះរតនៈត្រៃយ៍ សូមជួយតាមថែរក្សាអស់លោក លោកស្រីទាំងអស់ប្រកបតែនិងសេចក្តីសុខគ្រប់ប្រការទាំងអស់។